ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី

# FUTABA MICROFINANCE PLC.



របាយការណ៍ប្រចាំឆ្នាំ

# ២០១៨

# មាតិកា

របាយការណ៍ប្រចាំឆ្នាំ ២០១៨

| មាតិកា | ទំព័រ |
|---|---|


**បណ្ដាញប្រតិបត្តិការរបស់ ហ្វូតាបា**

ផែនទីតំបន់ប្រតិបត្តិការ ០២

**លទ្ធផលសម្រេចរបស់ ហ្វូតាបា**

ប្រតិបត្តិការសំខាន់ៗ ០៤

របាយការណ៍ហិរញ្ញវត្ថុសង្ខេប ០៥

បច្ចុប្បន្នភាពស្ថិតិបុគ្គលិក ០៧

**សារប្រធានក្រុមប្រឹក្សាភិបាល** ០៩

**សារនាយកប្រតិបត្តិ** ១១

**អំពីហ្វូតាបា**

ទិដ្ឋភាពសង្ខេបរបស់ ហ្វូតាបា ១៤

ទស្សនៈវិស័យ បេសកកម្ម និងតម្លៃស្នូល ១៥

ស្លាកសញ្ញារបស់ ហ្វូតាបា ១៧

ប្រវត្តិសង្ខេបរបស់ ហ្វូតាបា ១៩

**ព័ត៌មានអាជីវកម្ម**

ម្ចាស់ភាគទុនិក និងដើមទុន ២១

រចនាសម្ព័ន្ធ ២៣

ក្រុមប្រឹក្សាភិបាល ២៥

គណៈគ្រប់គ្រង ២៧

**សមិទ្ធផលអាជីវកម្ម**

សមិទ្ធផលឥណទានតាមវិស័យ ៣២

សមិទ្ធផលឥណទានតាមផលិតផល ៣៣

**ផលិតផល ហ្វូតាបា**

ឥណទានអាជីវកម្ម ៣៧

ឥណទានគេហដ្ឋាន ៣៧

ឥណទានប្រើប្រាស់ផ្ទាល់ខ្លួន ៣៨

ឥណទានកសិកម្ម ៣៨

ឥណទានសិក្សា ៣៩

ឥណទានបុគ្គលិក ៣៩

ឥណទាននិយោជិត ៤០

**ការអភិវឌ្ឍន៍បុគ្គលិក**

ការបណ្តុះបណ្តាល និងអភិវឌ្ឍបុគ្គលិក ៤២

ការចូលរួមវគ្គសិក្ខាសាលានៅខាងក្រៅ ៤៤

**ការគ្រប់គ្រងហានិភ័យ**

ការគ្រប់គ្រងហានិភ័យ និងការប្រតិបត្តិតាម ៤៦

សវនកម្មផ្ទៃក្នុង ៤៧

**របាយការណ៍សវនកម្មឯករាជ្យ**

របាយការណ៍របស់ក្រុមប្រឹក្សាភិបាល ៥០

របាយការណ៍របស់សវនករឯករាជ្យ ៥៥

តារាងតុល្យការ ៥៨

របាយការណ៍លទ្ធផល ៥៩

របាយការណ៍បម្រែបម្រួលមូលធន ៥៩

របាយការណ៍លំហូរសាច់ប្រាក់ ៦០

**ព្រឹត្តិការណ៍របស់ ហ្វូតាបា**

សិក្ខាសាលាប្រចាំឆ្នាំ២០១៨ ៦២

ពិពរណ៍ការងារជាមួយ UFYC ៦៥

**អតិថិជនរបស់ ហ្វូតាបា**

ប្រវត្តិអតិថិជន ៦៩

**ដៃគូសហប្រតិបត្តិការរបស់ ហ្វូតាបា** ៧២



# បណ្ដាញប្រតិបត្តិការ របស់ ហ្វូតាបា

# ផែនទីតំបន់ប្រតិបត្តិការ




### ១ សាខាការិយាល័យកណ្ដាល

អគារលេខ៧៩៥ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ

(៨៥៥) ២៣ ២២៤ ៣៣៣

### ២ សាខាខណ្ឌទួលគោក

#២៥ ផ្លូវលេខ៥៥៨ ភូមិ១ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ

(៨៥៥) ៧០ ៣១៧ ៣៣៣

### ៣ សាខាខណ្ឌពោធិ៍សែនជ័យ

#៧៨ក, ផ្លូវជាតិលេខ៤ ភូមិព្រៃស្វាយ សង្កាត់ចោមចៅ ទី៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

(៨៥៥) ៧០ ៣១៦ ៣៣៣

### ៤ សាខាក្រុងច្បារមន

#៤ ផ្លូវជាតិលេខ៤ ភូមិសំបួរ សង្កាត់ច្បារមន ក្រុងច្បារមន ខេត្តកំពង់ស្ពឺ

(៨៥៥) ៧០ ៣១៤ ៣៣៣




# លទ្ធផលសម្រេចរបស់ ហ្វូតាបា

១. ប្រតិបត្តិការសំខាន់ៗ

២. របាយការណ៍ហិរញ្ញវត្ថុសង្ខេប

៣. បច្ចុប្បន្នភាពស្ថិតិបុគ្គលិក

# ប្រតិបត្តិការសំខាន់ៗ

| បរិយាយ | ៣១ ធ្នូ ២០១៨ |
|---|---|
| ចំនួនការិយាល័យសាខា | ៤ |
| ចំនួនបុគ្គលិកសរុប | ៨០ |
| ចំនួនមន្ត្រីឥណទានសរុប | ១៩ |
| ចំនួនរាជធានី-ខេត្តប្រតិបត្តិការ | ១០ |
| ចំនួនស្រុកប្រតិបត្តិការ | ៣៨ |
| ចំនួនឃុំប្រតិបត្តិការ | ១៣៨ |
| ចំនួនភូមិប្រតិបត្តិការ | ៣២៣ |
| ចំនួនអតិថិជនឥណទានសរុប | ៧៨០ |
| សម្ពាធឥណទានសរុប (គិតជា ដុល្លារ) | ១២.៨០៤.៨០៨ |
| សម្ពាធឥណទានមានហានីភ័យសរុប (PAR %) | 0,00 % |
| សម្ពាធឥណទានសម្រាប់មន្ត្រីឥណទានម្នាក់ (គិតជា ដុល្លារ) | ៦៧៣.៩៣៧ |
| សម្ពាធឥណទានសម្រាប់បុគ្គលិកម្នាក់ (គិតជា ដុល្លារ) | ១៦០.០៦០ |
| សម្ពាធឥណទានគិតជាមធ្យម (គិតជា ដុល្លារ) | ១៦.៤១៦ |
| **ទ្រព្យសកម្មសរុប (គិតជា ដុល្លារ)** | **១៣.៧៨៤.២៦៨** |



# របាយការណ៍ហិរញ្ញវត្ថុសង្ខេប

| របាយការណ៍សមតុល្យ | ៣១ ធ្នូ ២០១៨ (ធ្វើសវនកម្មរួច), (គិតជា ដុល្លារ) |
|---|---|
| **ទ្រព្យសកម្មសរុប** | |
| សាច់ប្រាក់ក្នុងដៃ និងសាច់ប្រាក់នៅធនាគារ | ៦៥៩.៨៦១ |
| សម្ពាធឥណទានបានផ្តល់ជូនអតិថិជនសរុប | ១២.៨០៤,៨០៨ |
| ទ្រព្យសម្បត្តិ និងឧបករណ៍-សម្ភារៈសរុប | ១៩៤.៥៣៧ |
| ទ្រព្យសម្បត្តិផ្សេងៗ | ១២៥.០៦១ |
| **សរុបទ្រព្យសកម្ម** | **១៣.៧៨៤.២៦៨** |
| **បំណុល** | |
| បំណុលផ្សេងៗ និងសំវិធានធន | ១.៨៤៦.៨០៥ |
| កម្ចីរយៈពេលវែង និងកម្ចីរយៈពេលខ្លី | ៤.៩៤៦.៧៨២ |
| **បំណុលសរុប** | **៦.៧៩៣.៥៨៧** |
| **មូលធនភាគទុនិក** | |
| មូលធនភាគទុនិកសរុប | ៦.៩៩០.៦៨១ |
| **សរុបបំណុល និងមូលធនភាគទុនិក** | **១៣.៧៨៤.២៦៩** |



| របាយការណ៍ចំណូល និងចំណាយ | ៣១ ធ្នូ ២០១៨<br>(ធ្វើសវនកម្មរួច), (គិតជា ដុល្លារ) |
|---|---|
| ចំណូលការប្រាក់ និងថ្លៃសេវាផ្សេងៗ | ១.៦៩០.៦៤១ |
| ចំណាយប្រតិបត្តិការសរុប | ១.២៣៦.១២០ |
| **ប្រាក់ចំណេញសុទ្ធបន្ទាប់ពីបង់ពន្ធ** | **៤៥៤.៥២០** |

# បច្ចុប្បន្នភាពស្ថិតិបុគ្គលិក

ដើម្បីបន្តវឌ្ឍនភាពអាជីវកម្ម ក៏ដូចជាសម្រេចឱ្យបាននូវសមិទ្ធផលថ្មីៗបន្ថែមទៀតស្រប តាមគោលដៅយុទ្ធសាស្ត្ររយៈពេលវែងរបស់ខ្លួន ថ្នាក់ដឹកនាំគ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បានយកចិត្តទុកដាក់ជំរុញលើកទឹកចិត្ត ដោយលើកកម្ពស់ស្មារតីស្រឡាញ់ការងារ ចូលរួមអនុវត្តភារកិច្ចប្រកដោយការទទួលខុសត្រូវខ្ពស់រៀងៗខ្លួន។

មិនខុសពីឆ្នាំមុនៗ **ហ្វូតាបា** បានបន្តឱ្យតម្លៃខ្ពស់ទៅលើសារៈសំខាន់ នៃការរៀបចំធនធានមនុស្សឱ្យបានល្អប្រសើរស្របតាមតម្រូវការជាក់ស្តែង តាមរយៈការអភិវឌ្ឍមុខតំណែងតួនាទីនីមួយៗ ដែលត្រូវឆ្លងកាត់ការត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់ពីអ្នកគ្រប់គ្រងនូវសមិទ្ធផលសម្រេចបានជាក់ស្តែង ការខិតខំប្រឹងប្រែង ការប្រតិបត្តិក្រមសីលធម៌ល្អរបស់បុគ្គលិកម្នាក់ៗ ដើម្បីជំរុញលើកទឹកចិត្តឱ្យបានត្រឹមត្រូវប្រកបដោយប្រសិទ្ធភាព និងតម្លាភាព ក្នុងគោលដៅរក្សាបាននូវបុគ្គលិក សក្តានុពល និងទាក់ទាញបុគ្គលិកថ្មីៗដែលមានសមត្ថភាព ឱ្យមកចូលរួមក្នុងបេសកកម្មរបស់ ហ្វូតាបា។

បច្ចុប្បន្នបុគ្គលិកពេញម៉ោងកំពុងបម្រើការងារនៅ **ហ្វូតាបា** មានចំនួនសរុប ៨០នាក់ (បុរស ៥០នាក់ និងស្ត្រី ៣០នាក់) គិតត្រឹមបំណាច់ឆ្នាំ២០១៨ ដែលក្នុងនោះរួមមានដូចខាងក្រោម៖

## ភេទ




## ប្រភេទបុគ្គលិក



## ចលនាបុគ្គលិក




## បុគ្គលិកធ្វើការងារពេញម៉ោង





# សាររបស់ប្រធានក្រុមប្រឹក្សាភិបាល

*លោក ច្រឹក ផល្លី ប្រធានក្រុមប្រឹក្សាភិបាល*

យើងមើលឃើញថា នៅក្នុងឆ្នាំ២០១៨នេះ សេដ្ឋកិច្ចពិភពលោកមានកំណើនល្អបង្គួរ ដូចគ្នានឹងឆ្នាំ២០១៧ដែរ ទោះបីមានការប្រឈមនឹងភាពតានតឹងពាណិជ្ជកម្មរវាងចិន និងសហរដ្ឋអាមេរិក និងការជះឥទ្ធិពលនៃប្រក្រតីកម្មគោលនយោបាយរូបិយវត្ថុក្នុងប្រទេសអភិវឌ្ឍន៍មួយចំនួនក៏ដោយ។ ចំពោះការព្យាករណ៍នៃសេដ្ឋកិច្ចពិភពលោកថានឹងមានកំណើន ៣,៧% នៅឆ្នាំ២០១៨ និងឆ្នាំ២០១៩ យោងតាមមូលនិធិរូបិយវត្ថុអន្តរជាតិ។ ចំពោះសេដ្ឋកិច្ចកម្ពុជា កំណើនត្រូវបានប៉ាន់ស្មានថាសម្រេចបានក្នុងអត្រា ៧,៣% នៅឆ្នាំ២០១៨ ដែលខ្ពស់ជាងរយៈពេល ៤ឆ្នាំចុងក្រោយដោយគាំទ្រជាចម្បងពីកំណើនវិស័យកាត់ដេរ សំណង់ និងទេសចរណ៍ គួបផ្សំនឹងគោលនយោបាយប្រមូលពន្ធរបស់រដ្ឋាភិបាលកម្ពុជា ហើយអត្រាអតិផរណាមានកម្រិតទាបអាចគ្រប់គ្រងបានប្រមាណ ២,៥%។

កំណើនសេដ្ឋកិច្ចពិភពលោក នៅតែបានរួមចំណែកគាំទ្រដល់ការរីកចម្រើនវិស័យសេដ្ឋកិច្ចរបស់កម្ពុជា ខណៈពេលដែលជំនឿទុកចិត្ត

និងទស្សនវិស័យវិនិយោគិនមកលើកម្ពុជាមានភាពរឹងមាំ និងវិជ្ជមាន។ ក្នុងស្ថានភាពអំណោយផលនេះក៏ធ្វើឱ្យគ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី សម្រេចបាននូវសមិទ្ធផលធំៗគួរជាទីកត់សម្គាល់ដូចជាកំណើនអតិថិជន និងកំណើនសម្ពាធឥណទានមានការកើនឡើងជាបន្តបន្ទាប់ពីមួយឆ្នាំទៅមួយឆ្នាំ ដែលកំពុងបន្តដំណើររបស់ខ្លួនប្រកបដោយវិជ្ជមាន និងភាពរីកចម្រើនទៅថ្ងៃអនាគត។ ជាពិសេសក្នុងអំឡុងពាឆ្នាំកន្លងមកនេះ យើងបានរក្សាកម្រិតហានិភ័យនៃផលបត្រឥណទានក្នុងអត្រាសូន្យភាគរយ (0%) និងមិនមានអតិថិជនយឺតយ៉ាវដែលត្រូវលុបចេញពីបញ្ជីឡើយ ដែលនេះជាលទ្ធផលមួយដ៏ល្អប្រសើរបំផុតលើការគ្រប់គ្រងឥណទានដែលយើងបានបញ្ចេញនៅក្នុងឆ្នាំនីមួយៗ។ លទ្ធផលនេះបានដោយមានការចូលរួមសហការពីបុគ្គលិកគ្រប់ផ្នែក និងពិសេសផ្នែកឥណទានផ្ទាល់ ដែលបានខិតខំប្រឹងប្រែងក្នុងការគ្រប់គ្រង និងដោះស្រាយឱ្យបានទាន់ពេលវេលា។
ក្នុងនាមជាប្រធានក្រុមប្រឹក្សាភិបាល ខ្ញុំមានសេចក្តីសោមនស្សរីករាយឥតឧបមា ចំពោះសមិទ្ធផលដ៏ថ្លៃថ្លាដែលគ្រឹះស្ថានយើងខ្ញុំសម្រេចបាននាឆ្នាំកន្លងមក ជាពិសេសឆ្នាំ២០១៨នេះ ជាមួយនឹងសមិទ្ធផលដែលសម្រេចបានខាងក្រោមនេះ៖

* ទ្រព្យសកម្មសរុបចំនួន **១៣.៧៨៤.២៦៨ ដុល្លារ**
* សម្ពាធឥណទានសរុបចំនួន **១២.៨០៤.៨០៨ ដុល្លារ**
* អនុបាតឥណទានមិនដំណើរការស្មើនឹង **0.00%**
* អនុបាតសោធនភាពត្រូវបានរក្សាក្នុងកម្រិត **៤៩%**
* អតិថិជនខ្ចីឥណទានមានសរុបចំនួន **៧៨០នាក់**
* សាខាចំនួន **០៤** កំពុងធ្វើប្រតិបត្តិការរបស់ខ្លួនទៅតាមផែនការជាមួយនឹងតំបន់ប្រតិបត្តិការចំនួន **១០** ខេត្ត/ក្រុង **៣៨** ស្រុក/ខណ្ឌ **១៣៨** ឃុំ/សង្កាត់ និង **៣២៣** ភូមិ។

គ្រឹះស្ថាន **ហ្វូតាបា** បន្តការខិតខំសម្រិតសម្រាំងផ្តល់នូវផលិតផល និងសេវាកម្មប្រសើរបំផុតជូនអតិថិជនទាំងអស់ ពោលគឺអតិថិជន និង **ហ្វូតាបា** មានក្តីសុបិនរួមគ្នាតែមួយ។ បុគ្គលិកគ្រប់លំដាប់ថ្នាក់ទាំងអស់នៃគ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី សូមធ្វើគារវកិច្ចចំពោះអតិថិជនទាំងអស់របស់ខ្លួន ក្នុងការបំពេញភារកិច្ចលើបេសកកម្មរបស់ខ្លួនឱ្យទៅជាសកម្មភាពដ៏ពិតប្រាកដ ប្រកបដោយតម្លាភាព នឹងទំនួលខុសត្រូវខ្ពស់ ដើម្បីនាំមកនូវសមិទ្ធផលដ៏ធំធេងជូនដល់អតិថិជន ក៏ដូចជាសង្គមជាតិនៃកម្ពុជា ទាំងមូលផងដែរ។
ភាគទុនិកជប៉ុនរបស់យើងខ្ញុំ នៅតែមានសុឆន្ទៈចូលរួមចំណែកអភិវឌ្ឍធនធានមនុស្សជំនាន់ក្រោយនៃព្រះរាជាណាចក្រកម្ពុជា ហើយក៏មានការតាំងចិត្តខ្ពស់ថា នឹងបន្ថែមដើមទុនច្រើនជាងមុនមកឱ្យគ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ក្នុងឆ្នាំខាងមុខៗនេះ ទៅតាមផែនការយុទ្ធសាស្ត្រ និងលទ្ធភាពជាក់ស្តែងរបស់ខ្លួន។
ជាទីបញ្ចប់ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅសារជាថ្មីម្តងទៀត ជូនចំពោះអតិថិជនក៏ដូចជាជូនចំពោះអាជ្ញាធរគ្រប់លំដាប់ថ្នាក់ទាំងអស់ ជាពិសេសចំពោះធនាគារជាតិនៃកម្ពុជា ដែលតែងតែផ្តល់ការសហការ និងការគាំទ្រដល់គ្រឹះស្ថានយើងខ្ញុំ ដើម្បីចាត់ចែងនូវរាល់សកម្មភាពការងារទាំងអស់ប្រកបដោយតម្លាភាពរហូតមកដល់ពេលបច្ចុប្បន្ន និងនាពេលអនាគតផងដែរ។
យើងខ្ញុំសូមប្រសិទ្ធិពរជ័យ សិរីមង្គល វិបុលសុខ ចូរកើតមានដល់លោកអ្នក និងក្រុមគ្រួសារ សេចក្តីចម្រើនមានបាន ជោគជ័យគ្រប់ភារកិច្ចការងារ ជានិច្ចនិរន្តតរៀងទៅ។



**លោក ច្រឹក ផល្លី**
ប្រធានក្រុមប្រឹក្សាភិបាល



# សារនាយកប្រតិបត្តិ

លោក Junichi SASAKI នាយកប្រតិបត្តិ

ជូនចំពោះអតិថិជន និងដៃគូពាណិជ្ជកម្មជាទីគោរព!

គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ទទួលបានអាជ្ញាប័ណ្ណជាស្ថាប័នហិរញ្ញវត្ថុពីធនាគារជាតិនៃកម្ពុជា ហើយក៏បានចាប់ផ្តើមធ្វើសកម្មភាពអាជីវកម្ម នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ ដោយមើលឃើញពី ដំណើរការជាវិជ្ជមាននៃការប្រតិបត្តិ និងការគ្រប់គ្រងព្រមទាំងផែនការយុទ្ធសាស្ត្រវែងឆ្ងាយទៅថ្ងៃអនាគតរបស់គ្រឹះស្ថាន **ហ្វូតាបា** កាលពី ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨ ធនាគារជាតិនៃកម្ពុជាបានផ្តល់សុពលភាពអាជ្ញាប័ណ្ណរយៈពេល ៣ឆ្នាំបន្ថែមទៀត។ ហើយគិតមកត្រឹមឆ្នាំ ២០១៨នេះ គ្រឹះស្ថាន **ហ្វូតាបា** មានប្រតិបត្តិការអាជីវកម្មរបស់ខ្លួនប្រមាណជាង ៣ឆ្នាំ ហើយបាននិងកំពុងបន្តពង្រីកប្រតិបត្តិការរបស់ខ្លួនពីមួយថ្ងៃទៅមួយថ្ងៃប្រកបដោយវិជ្ជមាន ដែលមានការចូលរួមសហការពីថ្នាក់ដឹកនាំ និងបុគ្គលិកគ្រប់លំដាប់ថ្នាក់ ជាពិសេសការគាំទ្រពីអតិថិជនលើការប្រើប្រាស់សេវាកម្ម និងផលិតផលរបស់គ្រឹះស្ថាន **ហ្វូតាបា**។

បើគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ យើងមានការិយាល័យសាខាចំនួន ០៤ ខេត្ត-រាជធានីរួមមានទីស្នាក់ការកណ្តាល (រួមជាមួយសាខាការិយាល័យកណ្តាល) សាខាខណ្ឌទួលគោក សាខាខណ្ឌពោធិ៍សែនជ័យ និងសាខាក្រុងច្បារមន ចំពោះអតិថិជនដែលបាននិងកំពុងទទួលកម្ចីមានសរុប ៧៨០នាក់

ជាមួយនឹងផលបត្រឥណទានសរុប ១២.៨០៤.៨០៨ ដុល្លារអាមេរិក ក្រោមការគ្រប់គ្រងរបស់មន្ត្រីឥណទានចំនួន ១៩នាក់ និងកម្រិតហានិភ័យនៃផលបត្រ ឥណទានក្នុងអត្រាសូន្យ (0%) ភាគរយ និងមិនមានអតិថិជនយឺតយ៉ាវដែលត្រូវលុបចេញពីបញ្ជីឡើយ។ លទ្ធផលនេះ មិនមានការកើនឡើងច្រើនទេបើប្រៀបធៀបសមិទ្ធផលក្នុងឆ្នាំ២០១៧ ដោយសារតែក្នុងឆ្នាំ២០១៨ ត្រូវពង្រឹងប្រព័ន្ធនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ខ្លួនដើម្បីឱ្យការប្រតិបត្តិមានភាពរឹងមាំ ដោយត្រូវផ្តោតលើការបណ្តុះបណ្តាលចំណេះជំនាញបុគ្គលិក ការកែសម្រួលរចនាសម្ព័ន្ធ និងបច្ចុប្បន្នភាពលើគោលការណ៍នីតិវិធីនានា ព្រមទាំងត្រូវប្រតិបត្តិតាមច្បាប់ ឬបទប្បញ្ញត្តិដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា និងក្រសួងពាក់ព័ន្ធ។

យើងសង្ឃឹម និងជឿជាក់ថា គ្រឹះស្ថានយើងខ្ញុំនឹងក្លាយជាមាគ៌ាសម្រាប់អ្នកជំនាន់ក្រោយកម្ពុជា ដែលសម្រេចយកភាពត្រឹមត្រូវស្មើគ្នា និងរក្សាឲ្យបាននូវតម្លាភាពជាមូលដ្ឋានក្នុងវិស័យសេវាហិរញ្ញវត្ថុ។ គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បានការគាំទ្រមូលនិធិពីភាគទុនិកឯកកម្មសិទ្ធិនៃប្រទេសជប៉ុន ដែលយើងខ្ញុំអាចចាត់ចែងប្រកបដោយភាពស្ទាត់ជំនាញ និងផ្តល់សេចក្តីសម្រេចចិត្តបានយ៉ាងឆាប់រហ័ស ដើម្បីបំពេញតាមតម្រូវការអតិថិជន។

ចក្ខុវិស័យរបស់យើងខ្ញុំ គឺធ្វើខ្លួនឲ្យក្លាយជាគ្រឹះស្ថានហិរញ្ញវត្ថុឈានមុខមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីរួមចំណែកអភិវឌ្ឍសង្គម និងកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពក្នុងពេលបច្ចុប្បន្ន និងពេលអនាគតតាមរយៈការធ្វើឲ្យមានលំនឹងស្ថិរភាព តម្លាភាពលើផ្នែកទីផ្សារហិរញ្ញវត្ថុនៅកម្ពុជា និងផែនការយុទ្ធសាស្រ្តរយៈពេលវែងដែលនឹងពង្រីកតំបន់ប្រតិបត្តិឱ្យបានទូលំទូលាយបន្ថែមទៀតនៅតាមបណ្តាខេត្តផ្សេងទៀត ដែលជាបំណងប្រាថ្នាដ៏សុចរិត ក៏ដូចជាគោលដៅរបស់គ្រឹះស្ថានយើងខ្ញុំផងដែរ។

ស្របតាមចក្ខុវិស័យរយៈពេលវែង និងការរំពឹងទុកអំពីភាពវិជ្ជមាននៃវឌ្ឍនភាពទីផ្សារហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា គ្រឹះស្ថាន **ហ្វូតាបា** នឹងបន្តអនុវត្តផែនការគោល និងផែនការយុទ្ធសាស្រ្តរយៈពេលវែងរបស់ខ្លួន ដើម្បីពង្រីកនូវសក្តានុពលរបស់ខ្លួនគ្របដណ្តប់លើវិសាលភាពទីផ្សារឱ្យបានទូលំទូលាយ និងឆ្លើយតបទៅនឹងកំណើននៃតម្រូវការឥណទានពីសំណាក់អតិថិជនក្នុងតំបន់ និងការរីកចម្រើនរបស់ប្រទេសនាពេលបច្ចុប្បន្ន និងអនាគត។

ក្តីសុបិនយើងខ្ញុំ គឺផ្តល់ការគាំទ្រច្រើនបែបជូនដល់អតិថិជន ក៏ដូចជាសង្គមដែលបង្កើតជាមូលដ្ឋានហិរញ្ញវត្ថុដើម្បីសាងអនាគតដ៏ត្រចះត្រចង់របស់ពួកគាត់។

លើសពីនេះ ខ្ញុំសូមគូសបញ្ជាក់ឡើងវិញថា ការរក្សាឲ្យបាននូវសេវាល្អបំផុត និងភាពទទួលខុសត្រូវដ៏ល្អឥតខ្ចោះនេះធ្វើឲ្យគ្រឹះស្ថានយើងខ្ញុំមានភាពខុសប្លែកពីសេវារបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដទៃទៀត។ ជាមួយនឹងសកម្មភាពផ្តល់ហិរញ្ញប្បទានយើងខ្ញុំផ្តោតលើទស្សនៈ "ជាដៃគូទុកចិត្តល្អឥតខ្ចោះរបស់អតិថិជន" តាមរយៈការផ្តល់សេវាហិរញ្ញវត្ថុសម្បូរបែប រួមជាមួយនឹងសេវាកម្មប្រកបដោយជំនាញវិជ្ជាជីវៈ ដែលសមស្របទៅនឹងសំណើ និងតម្រូវការរបស់អតិថិជននីមួយៗដែលអញ្ជើញមកដាក់ ពាក្យស្នើសុំក្នុងស្ថានភាពផ្សេងៗគ្នា និងទីតាំងខុសៗគ្នា។

អតិថិជនរបស់យើងខ្ញុំ នឹងទទួលបាននូវស្ថិរភាពហិរញ្ញវត្ថុលើការពង្រីកមុខរបរ និងអាជីវកម្មរបស់ខ្លួន តាមរយៈការផ្តល់កញ្ចប់សេវាប្រសើរបំផុត ដែលមានការប្តេជ្ញាចិត្តពីបុគ្គលិកជំនាញ និងប្រកបដោយវិជ្ជាជីវៈខ្ពស់ ដើម្បីផ្តល់ជម្រើសហិរញ្ញវត្ថុសមស្របជាច្រើនបែបមកបំពេញ តម្រូវការរបស់អតិថិជន។

គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ផ្តល់នូវកញ្ចប់សេវាហិរញ្ញវត្ថុច្រើនបែបយ៉ាងមានដូចជា ឥណទានអាជីវកម្ម ឥណទានកសិកម្ម ឥណទានគេហដ្ឋាន ឥណទានសម្រាប់ប្រើប្រាស់ ឥណទានបុគ្គលិក ឥណទានសិក្សា និងឥណទាននិយោជិត។ នៅក្នុងឆ្នាំ២០១៨នេះ គ្រឹះស្ថានបានបង្កើតផលិតផលមួយបន្ថែមទៀតគឺ ឥណទាននិយោជិត ដែលផ្តោតសំខាន់ទៅលើអ្នកធ្វើការ ឬនិយោជិតក្រុមហ៊ុន ឬ សហគ្រាសនានាដែលមានតម្រូវការប្រាក់កម្ចី។ ចំពោះឥណទានបុគ្គលិក និងកម្ចីសម្រាប់ការសិក្សា ត្រូវបានផ្តល់ជូនក្នុងអត្រាការប្រាក់ទាបបំផុតជាមួយគ្នា និងសេវាល្អឥតខ្ចោះដែលមិនធ្លាប់មានក្នុងគោលដៅចូលរួមលើកស្ទួយផ្នែកសង្គមគាំទ្រជីវភាពគ្រួសាររបស់បុគ្គលិក និងអភិវឌ្ឍវិស័យធនធានមនុស្ស។ តទៅមុខទៀត គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី យើងខ្ញុំក៏សូមផ្តល់ជូននូវសេវាដ៏សម្បូរបែប និងប្រកបដោយភាពច្នៃប្រឌិតខ្ពស់លើដំណោះស្រាយហិរញ្ញវត្ថុថ្មីៗ ជូនចំពោះអតិថិជនចាស់ និងថ្មីទាំងអស់។

គ្រឹះស្ថានយើងខ្ញុំរង់ចាំសម្រេចក្តីសុបិនរបស់លោកអ្នកគ្រប់ទីកន្លែងដែលយើងមានកិច្ចសហការរួមគ្នា ដើម្បីសម្រេចនូវគោលបំណងរួមរវាងលោកអ្នក និងគ្រឹះស្ថាន "ក្តីសុបិនរបស់លោកអ្នកជាក្តីសុបិនយើងខ្ញុំ" "អនាគតរបស់លោកអ្នកក៏ជាអនាគតរបស់យើងខ្ញុំផងដែរ"។

យើងខ្ញុំរីករាយស្វាគមន៍ផ្តល់សេវាយ៉ាងកក់ក្តៅ និងជាទីទុកចិត្តជូនអតិថិជនទាំងអស់ គ្រប់ពេលវេលាដែលលោកអ្នកត្រូវការ។ សូមសុបិនរបស់លោកអ្នកក្លាយជាការពិត។

**លោក Junichi SASAKI**

នាយកប្រតិបត្តិ




# អំពីហ្វូតាបា

១. ទិដ្ឋភាពសង្ខេបរបស់ ហ្វូតាបា

២. ទស្សនៈវិស័យ បេសកកម្ម និងតម្លៃស្នូល

៣. ស្លាកសញ្ញារបស់ ហ្វូតាបា

៤. ប្រវត្តិសង្ខេបរបស់ ហ្វូតាបា

# ទិដ្ឋភាពសង្ខេបរបស់ ហ្វូតាបា

គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បានចាប់ផ្តើមប្រតិបត្តិការរបស់ខ្លួននាចុងឆ្នាំ២០១៥ ដែលបានទទួលអាជ្ញាប័ណ្ណប្រកបអាជីវកម្មគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ កាលពី ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ ពីធនាគារជាតិនៃកម្ពុជា ក្រោមបេសកកម្ម និងទស្សនៈវិស័យដ៏ច្បាស់លាស់របស់ខ្លួន ដែលចង់ក្លាយខ្លួនជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឈានមុខគេនៅក្នុងប្រទេសកម្ពុជាផងដែរ។ ក្រោយមកនៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨ ធនាគារជាតិនៃកម្ពុជា បានអនុញ្ញាតបន្តសុពលភាពអាជ្ញាប័ណ្ណជូនគ្រឹះស្ថាន **ហ្វូតាបា** រយៈពេល ៣ឆ្នាំ បន្ថែមទៀត។ ចាប់តាំងពីឆ្នាំ២០១៦ ក្រុមហ៊ុន AZUMA & Co., Ltd. (ជាក្រុមហ៊ុនជប៉ុន) ក៏បានក្លាយជាភាគទុនិកកាន់កាប់ភាគហ៊ុន ១០០% របស់គ្រឹះស្ថាន **ហ្វូតាបា**។

បើគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ យើងមានបុគ្គលិកសរុបចំនួន ៨០នាក់ ស្រីចំនួន ៣០នាក់ និងប្រុសចំនួន ៥០នាក់ ដែលកំពុងបម្រើការងារនៅការិយាល័យកណ្តាល និងសាខាចំនួន ០៤ ខេត្ត-រាជធានីរួមមាន សាខាការិយាល័យកណ្តាល សាខាខណ្ឌទួលគោក សាខាខណ្ឌពោធិ៍សែនជ័យ និងសាខាក្រុងច្បារមន ចំពោះអតិថិជនដែលបាននិង កំពុងទទួលកម្ចីមានសរុប ៧៨០នាក់ ជាមួយនឹងផលប័ត្រឥណទានសរុប ១២.៨០៤.៨០៨ ដុល្លារអាមេរិក ក្រោមការគ្រប់គ្រងរបស់មន្ត្រីឥណទានចំនួន ១៩នាក់ ដែលមានការកើនឡើងជាបន្តបន្ទាប់ពីមួយឆ្នាំទៅមួយឆ្នាំ អាចបញ្ជាក់ឱ្យឃើញថា គ្រឹះស្ថាន **ហ្វូតាបា** បាន និងកំពុងបន្តដំណើររបស់ខ្លួនប្រកបដោយវិជ្ជមាន និងភាពរីកចម្រើនទៅថ្ងៃអនាគត។ ជាពិសេសក្នុងអំឡុង ៣ឆ្នាំកន្លងមកនេះ យើងបានរក្សាកម្រិតហានិភ័យនៃផលបត្រឥណទាន និងអតិថិជនយឺតយ៉ាវដែលត្រូវលុបចេញពីបញ្ជីក្នុងអត្រាសូន្យ (០%) ភាគរយ ដែលនេះជាលទ្ធផលមួយដ៏ល្អប្រសើរបំផុតលើការគ្រប់គ្រងឥណទានដែលយើងបានបញ្ចេញនៅក្នុងឆ្នាំនីមួយៗ។

នៅក្នុងការផ្តល់ប្រាក់កម្ចីជាមួយការផ្តល់សេវា និងផលិតផលរបស់ខ្លួននោះ គ្រឹះស្ថាន **ហ្វូតាបា** ក៏មានផលិតផលសំខាន់មួយ គឺឥណទានបុគ្គលិក ដោយបានផ្តល់ក្នុងអត្រាការប្រាក់ទាបបំផុតដែលជាផ្នែកមួយជួយគាំទ្រដល់ជីវភាពរបស់បុគ្គលិក និងជាគោលដៅចម្បងរបស់ក្រុមប្រឹក្សាភិបាលដែលចង់ឱ្យបុគ្គលិកមានការចូលរួម និងរួមរស់ជាមួយគ្រឹះស្ថានឱ្យបានយូរអង្វែងទៅថ្ងៃខាងមុខ។

ស្របតាមចក្ខុវិស័យរយៈពេលវែង និងការរំពឹងទុកអំពីភាពវិជ្ជមាននៃវឌ្ឍនភាពទីផ្សារហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា គ្រឹះស្ថាន **ហ្វូតាបា** នឹងបន្តអនុវត្តផែនការគោល និងផែនការយុទ្ធសាស្ត្ររយៈពេលវែងរបស់ខ្លួន ដើម្បីពង្រីកនូវសក្តានុពលរបស់ខ្លួនគ្របដណ្តប់លើវិសាលភាពទីផ្សារឱ្យបានទូលំទូលាយ និងឆ្លើយតបទៅនឹងកំណើននៃតម្រូវការឥណទានពីសំណាក់អតិថិជនក្នុងតំបន់ និងការរីកចម្រើនរបស់ប្រទេសនាពេលបច្ចុប្បន្ន និងអនាគត។



# ទស្សនៈវិស័យ បេសកកម្ម និងតម្លៃស្នូល

**ទស្សនៈវិស័យ**

ជាស្ថាប័នហិរញ្ញវត្ថុឈានមុខគេក្នុងប្រទេសកម្ពុជា ដែលលើកស្ទួយឲ្យល្អប្រសើរនូវកម្រិតជីវភាពរស់នៅរបស់អតិថិជន នាពេលបច្ចុប្បន្ន និងអ្នកជំនាន់ថ្មី។

**បេសកកម្ម**

ផ្តល់ជូននូវសេវាកម្មហិរញ្ញវត្ថុដែលទុកចិត្ត បំផុតទៅកាន់សហគ្រាសខ្នាតមធ្យម ខ្នាតតូច ខ្នាតតូចបំផុត និងរូបវន្តបុគ្គល ដោយបង្កើតនូវទីផ្សារដែលមានស្ថិរភាព ដើម្បីគាំទ្រទាំងអតិថិជន នាពេលបច្ចុប្បន្ន និងអ្នកជំនាន់ថ្មី ព្រមទាំងចូលរួមក្នុងសកម្មភាពសង្គម ដើម្បីសម្រេចនូវគោលបំណង ឬ ក្តីសុបិនរបស់ពួកគាត់ ជាមួយអនាគតដ៏ប្រសើរ។



## តម្លៃស្នូល



# ស្លាកសញ្ញារបស់ ហ្វូតាបា

## និមិត្តសញ្ញា និងអត្ថន័យ

និមិត្តសញ្ញាសម្គាល់ នេះ គឺសំដៅលើត្រួយនៃពន្លករបស់គ្រាប់ធញ្ញជាតិដ៏តូចមួយ ដែលបែកពន្លកចេញពីស្រទាប់ដី។ ត្រួយនៃពន្លករបស់គ្រាប់ធញ្ញជាតិដ៏តូចនេះ អាចលូតលាស់ជាឈើដ៏ធំមួយដើមនាពេលអនាគតដ៏ឆាប់រហ័ស គឺអាស្រ័យលើការខិតខំបីបាច់ ថែទាំ និងដាក់ជីយ៉ាង ល្អិតល្អន់របស់យើងទាំងអស់គ្នា។

ក្នុងន័យនេះ យើងខ្ញុំជាគ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ប្រៀបបានទៅនឹងគ្រឹះស្ថានហិរញ្ញវត្ថុដ៏តូចមួយ ដែលទើបតែចាប់ផ្តើមប្រតិបត្តិការរបស់ខ្លួន លើវិស័យហិរញ្ញវត្ថុក្នុងព្រះរាជាណាចក្រកម្ពុជាផងដែរ។

ហើយយើងខ្ញុំអាចអភិវឌ្ឍជាធនាគារឈានមុខមួយ ក្នុងព្រះរាជាណាចក្រកម្ពុជា នាពេលអនាគតខាងមុខ ដើម្បីផ្តល់សេវាហិរញ្ញវត្ថុប្រកបដោយគុណភាពខ្ពស់ ធានាឲ្យបាននូវស្ថិរភាព និងផ្តល់អនាគតដ៏ត្រចះត្រចង់ បម្រើជូនសាធារណៈជនទាំងអស់របស់គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ឬក៏ធនាគារ **ហ្វូតាបា** ប្រៀបដូចជាត្រួយនៃពន្លកធញ្ញជាតិដ៏តូច រីកលូតលាស់ទៅជាដើមឈើដ៏ធំនា ពេលអនាគតដ៏ខ្លីខាងមុខ។

គ្រឹះស្ថានយើងខ្ញុំអាចអភិវឌ្ឍឆាប់រហ័សប្រៀបដូចនឹងដើមឈើដ៏ធំ គឺអាស្រ័យលើបុគ្គលិកគ្រប់លំដាប់ថ្នាក់នីមួយៗនៃគ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី មានកិច្ចខិតខំប្រឹងប្រែង ប្រកបដោយស្មារតីយកចិត្តទុកដាក់ខ្ពស់ផងដែរ ហើយក៏ពឹងផ្អែកលើទំហំទុន ដែលគ្រឹះស្ថានទទួលបានពីភាគទុនិករបស់ខ្លួន ដើម្បីបម្រើសេចក្តីត្រូវការរបស់អតិថិជនយើងខ្ញុំ។

## ពណ៌

ពណ៌បៃតងនៃត្រួយពន្លកគ្រាប់ធញ្ញជាតិ គឺសំដៅភាពយកចិត្តទុកដាក់លើបរិស្ថានភាព សុខដុមរវាងកំណើនសេដ្ឋកិច្ច និងនិរន្តរភាពបរិស្ថាន នាពេលបច្ចុប្បន្ន និងតទៅអនាគតសម្រាប់ជំនាន់ក្រោយ។

## ពាក្យស្លោក

**សុបិនក្លាយជាការពិត**

ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី
FUTABA MICROFINANCE PLC.



# ប្រវត្តិសង្ខេបរបស់ ហ្វូតាបា

៤ សាខា

- សាខាការិយាល័យកណ្ដាល - សាខាខណ្ឌទួលគោក
- សាខាខណ្ឌពោធិ៍សែនជ័យ - សាខាក្រុងច្បារមន

៧.០០០.០០០ ដុល្លារ

**ចំនួនសាខា**
**និង**
**ដើមទុន**

គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ត្រូវបានបង្កើតឡើងស្របតាមគោលបំណង និងក្ដីសុបិន របស់ភាគទុនិកតាមរយៈគំនិតផ្ដួចផ្ដើម ព្រមទាំងការប្ដេជ្ញាចិត្តខ្ពស់ ភាគទុនិកបានជម្នះនូវរាល់ឧបសគ្គទាំងឡាយរហូតទទួលបានអាជ្ញាប័ណ្ណជាផ្លូវការពីធនាគារជាតិនៃកម្ពុជា លេខ ម.ហ-៦៤ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥។

នៅដើមឆ្នាំ២០១៦ គ្រឹះស្ថានក៏ចាប់ផ្ដើមប្រតិបត្តិការអាជីវកម្មជាមួយនឹងដើមទុនដំបូង $ ១.០០០.០០០ ដោយទទួលបានការគាំទ្រយ៉ាងខ្លាំងពីសំណាក់អតិថិជនជាច្រើន ដែលបង្ហាញពីភាពជោគជ័យមិត្រចុះត្រចង់។ ជាមួយគ្នានេះផងដែរ ក្នុងឆ្នាំ២០១៦នេះ ក្រុមហ៊ុន AZUMA & Co., Ltd. ក៏បានក្លាយជាភាគទុនិកថ្មីរបស់គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី។ ក្រុមហ៊ុន AZUMA & Co., Ltd. ជាក្រុមហ៊ុនជប៉ុន ដែលមានគោលគំនិតស្របគ្នាក្នុងការគាំទ្រលើកស្ទួយកម្រិតជីវភាពស្ថង់ដាររស់នៅជូនដល់ប្រជាពលរដ្ឋកម្ពុជា ជាពិសេសចូលរួមអភិវឌ្ឍន៍មនុស្សជំនាន់ថ្មី តាមរយៈការផ្ដល់សេវាហិរញ្ញវត្ថុប្រកបដោយគុណភាព ស្ថិរភាព និងតម្លាភាពនៃទីផ្សារ។

ស្របតាមចក្ខុវិស័យរយៈពេលវែង និងការរំពឹងទុកអំពីវិជ្ជមាននៃវឌ្ឍនភាពទីផ្សារហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី នឹងបន្តអនុវត្តផែនការគោលរបស់ខ្លួន ដើម្បីសម្រេចឱ្យបាននូវវត្ថុបំណងនៃក្ដីសុបិនរបស់ភាគទុនិក។ ជាក់ស្ដែងគ្រឹះស្ថានបានបង្កើតការិយាល័យសាខាថ្មីចំនួនបី (៣) បន្ថែមទៀតនៅចុងឆ្នាំ២០១៦ ដើម្បីពង្រីកនូវសក្ដានុពលរបស់

ខ្លួនគ្របដណ្តប់លើវិសាលភាពទីផ្សារទូលំទូលាយ និងឆ្លើយតបទៅតាមកំណើននៃតម្រូវការឥណទានពីសំណាក់អតិថិជនក្នុងតំបន់។ សាខាបើកថ្មីទាំងបី (៣) នោះ ត្រូវបានទទួលអាជ្ញាប័ណ្ណ ពីធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៦។ ដោយមើលឃើញពីដំណើរការជាវិជ្ជមាន នៃការប្រតិបត្តិ និងការគ្រប់គ្រង ព្រមទាំងផែនការយុទ្ធសាស្រ្តវែងឆ្ងាយទៅថ្ងៃអនាគតរបស់គ្រឹះស្ថាន **ហ្វូតាបា** កាលពីថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨ ធនាគារជាតិនៃកម្ពុជាបានផ្តល់សុពលភាពអាជ្ញាប័ណ្ណរយៈពេល ៣ឆ្នាំ បន្ថែមទៀត។ យើងឃើញថាគ្រឹះស្ថាន **ហ្វូតាបា** មិនមានការបន្ថែមដើមទុន និងពង្រីកប្រតិបត្តិការសាខាទៀតទេក្នុងឆ្នាំ២០១៧ និងឆ្នាំ២០១៨ ដោយសារតែគ្រឹះស្ថានត្រូវពង្រឹងលើប្រព័ន្ធនៃការត្រួតពិនិត្យផ្ទៃក្នុង និងការអនុវត្តការងារនានាឱ្យមានប្រសិទ្ធភាពខ្ពស់។




## ការវិវឌ្ឍន៍នៃដើមទុន





# ព័ត៌មានអាជីវកម្ម

លោក Yosuke SASAKI តំណាងភាគទុនិក

១. ម្ចាស់ភាគទុនិក និងដើមទុន

២. រចនាសម្ព័ន្ធ

៣. ក្រុមប្រឹក្សាភិបាល

៤. គណៈគ្រប់គ្រង

# ម្ចាស់ភាគទុនិក និងដើមទុន

**AZUMA & Co.,Ltd.** ជាភាគទុនិកឯកកម្មសិទ្ធិកាន់កាប់លើភាគហ៊ុន ១០០% របស់គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី សូមសម្តែងនូវសុឆន្ទៈ ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រ របស់ពលរដ្ឋ កម្ពុជា។ **AZUMA & Co.,Ltd.** ជាសហគ្រាសជប៉ុនសុទ្ធសាធ ដែលរូបខ្ញុំ **Yosuke SASAKI** ជាជនជាតិជប៉ុន ទទួលកាន់កាប់លើភាគហ៊ុន១០០% និងមានតួនាទីជាប្រធាននាយក នៃសហគ្រាស **AZUMA & Co.,Ltd.** យើងខ្ញុំមានកិត្តិយសក្រៃលែងក្នុងនាមជានីតិបុគ្គលនៃសហគ្រាស **AZUMA & Co.,Ltd.** ដែលបានចូលរួមចំណែកក្នុងនាមជាអ្នកផ្តល់ហិរញ្ញប្បទាន និងថែរក្សាអ្នកជំនាន់ក្រោយ ក៏ដូចជាជួយលើកកម្ពស់កម្រិតស្តង់ដារការរស់នៅរបស់ពលរដ្ឋកម្ពុជាឲ្យកាន់តែប្រសើរឡើងៗ នៅព្រះរាជាណាចក្រកម្ពុជា ដោយផ្អែកលើគោលការណ៍តម្លាភាពប្រសិទ្ធភាពនិងការផ្តល់សេវាហិរញ្ញប្បទានប្រកបដោយនិរន្តរភាពយូរអង្វែងរបស់គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី យើងខ្ញុំ។





# រចនាសម្ព័ន្ធ



ម្ចាស់ភាគហ៊ុនិក
ក្រុមប្រឹក្សាភិបាល
អភិបាល
នាយកប្រតិបត្តិ
ទីប្រឹក្សា នាយកប្រតិបត្តិ
ជំនួយការ នាយកប្រតិបត្តិ
ជំនួយការ នាយកប្រតិបត្តិ
នាយកដ្ឋានឥណទាន នាយកនាយកដ្ឋានឥណទាន
នាយកដ្ឋានប្រតិបត្តិការ នាយក នាយកដ្ឋានប្រតិបត្តិការ
នាយក នាយកដ្ឋានហិរញ្ញវត្ថុ នាយិកាស្តីទីនាយកដ្ឋានហិរញ្ញវត្ថុ
នាយកដ្ឋានព័ត៌មានវិទ្យា នាយក នាយកដ្ឋានព័ត៌មានវិទ្យា
នាយកនាយកដ្ឋានធនធានមនុស្ស និងរដ្ឋបាល
នាយករង នាយកដ្ឋានច្បាប់ និងប្រតិបត្តិតាម
ប្រធានផ្នែកទីផ្សារ
ប្រធានផ្នែកបេឡាធិការ
មន្ត្រីភាគឥណទានជាន់ខ្ពស់
មន្ត្រីត្រួតពិនិត្យឥណទានជាន់ខ្ពស់
មន្ត្រីប្រតិបត្តិការជាន់ខ្ពស់
គណនេយ្យករជាន់ខ្ពស់
សវនករផ្ទៃក្នុងជាន់ខ្ពស់
មន្ត្រីផ្នែកទីផ្សារ
គណនេយ្យករ
មន្ត្រីពន្ធ
មន្ត្រីព័ត៌មានវិទ្យា
មន្ត្រីព័ត៌មានវិទ្យា
មន្ត្រីធនធានមនុស្ស និងរដ្ឋបាល
នាយកសាខា ការិយាល័យកណ្តាល
នាយករងសាខា ខណ្ឌទួលគោក
នាយកសាខា ខណ្ឌពោធិ៍សែនជ័យ
នាយកសាខា ក្រុងច្បារមន




លោក **ច្រឹក ផល្លី** ប្រធានក្រុមប្រឹក្សាភិបាល

លោក **ច្រឹក ផល្លី** កើតនៅទីក្រុងភ្នំពេញ ឆ្នាំ១៩៨១ សញ្ជាតិខ្មែរ បានចាប់ផ្តើមការងារជាមួយគ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ចាប់តាំងពីខែកក្កដា ឆ្នាំ២០១៥ ក្នុងតួនាទីជាសមាជិកក្រុមប្រឹក្សាភិបាល ក្រោយមកលោកត្រូវបានតែងតាំង និងទទួលស្គាល់ជាប្រធានក្រុមប្រឹក្សាភិបាលនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៦។ លោកមានបទពិសោធន៍ជាង ១៥ឆ្នាំ ខាងផ្នែកគ្រប់គ្រង ដែលក្នុងរយៈពេល ៥ឆ្នាំ លោកបានបំពេញតួនាទីជាប្រធានគ្រប់គ្រងផ្នែកទីផ្សារនៅក្រុមហ៊ុន Futaba Co.,Ltd. ក្នុងឆ្នាំ២០០៧ លោកត្រូវបានតែងតាំងជានាយកចាត់ការទូទៅ ហើយបានបម្រើការងាររហូតមកដល់បច្ចុប្បន្ននេះ។ លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកគ្រប់គ្រងពាណិជ្ជកម្ម ពីសាកលវិទ្យាល័យន័រតុន។ លោកត្រូវបានតែងតាំងជាប្រធានក្រុមប្រឹក្សាភិបាលនៃគ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ចាប់តាំងពីខែកក្កដា ឆ្នាំ២០១៥ មក។



លោក Yusoke SASAKI
សមាជិកក្រុមប្រឹក្សាភិបាល

លោក **Yusoke SASAKI** កើតនៅទីក្រុង **KANAGAWA** ប្រទេសជប៉ុន ឆ្នាំ១៩៨៣ សញ្ជាតិជប៉ុន ត្រូវបានទទួលស្គាល់ជាសមាជិកក្រុមប្រឹក្សាភិបាល នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៦។ ក្រុមហ៊ុន **AZUMA & CO.,LTD.** ជាក្រុមហ៊ុនជប៉ុន និងជាម្ចាស់ភាគហ៊ុន ១00% ដែលតំណាងពេញច្បាប់ ដោយលោក **Yusoke SASAKI** មានតួនាទីជាប្រធាននាយក។

ក្រុមហ៊ុន **AZUMA & CO.,LTD.** ជាក្រុមហ៊ុនជប៉ុន មានគោលគំនិតស្របគ្នាក្នុងការគាំទ្រ លើកស្ទួយកម្រិតជីវភាពស្តង់ដាររស់នៅជូនដល់ពលរដ្ឋកម្ពុជា ជាពិសេសចូលរួមអភិវឌ្ឍន៍មនុស្សជំនាន់ថ្មី តាមរយៈការផ្តល់សេវាហិរញ្ញវត្ថុប្រកបដោយគុណភាព ស្ថិរភាព និងតម្លាភាពនៃទីផ្សារ។



លោក Junichi SASAKI
សមាជិកក្រុមប្រឹក្សាភិបាល

លោក **Junichi SASAKI** កើតនៅទីក្រុង **KANAGAWA** ប្រទេសជប៉ុន ឆ្នាំ១៩៤៩ សញ្ជាតិជប៉ុន ត្រូវបានទទួលស្គាល់ជាសមាជិកក្រុមប្រឹក្សាភិបាល នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៧។ លោក **Junichi SASAKI** បានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យតូក្យូ នៅឆ្នាំ ១៩៧៥ បច្ចុប្បន្នជាប្រធាន និងជាភាគទុនិក ១00% នៃ **FutureBud International Co.,Ltd.** នៃប្រទេសជប៉ុន ។



# គណៈគ្រប់គ្រង

លោក Junichi SASAKI បានបញ្ចប់ការសិក្សា ពីសាកលវិទ្យាល័យតូក្យូ នៅក្នុងឆ្នាំ ១៩៧៥ បច្ចុប្បន្ន ជាប្រធាន និងជាភាគទុនិក ១០០% នៃ FutureBud International Co.,Ltd. នៃប្រទេសជប៉ុន។



បណ្ឌិត ចាប រតនា
ទីប្រឹក្សានាយកប្រតិបត្តិ

បណ្ឌិត **ចាប រតនា** បានចូលបម្រើការងារជាមួយ **ហ្វូតាបា** ក្នុងខែមករា ឆ្នាំ២០១៥ ជាទីប្រឹក្សាហិរញ្ញវត្ថុក្នុងស្រុក បន្ទាប់មកគាត់ក៏មកកាន់តំណែងជានាយករង នាយកប្រតិបត្តិ នៅខែតុលា ឆ្នាំ២០១៥។ គាត់បានបញ្ចប់ថ្នាក់បណ្ឌិតគ្រប់ គ្រងពាណិជ្ជកម្ម និងថ្នាក់អនុបណ្ឌិតគ្រប់គ្រងការអប់រំនៅសាកលវិទ្យាល័យ បៀលប្រាយ។ អស់រយៈពេលជាង ២៥ឆ្នាំ គាត់ទទួលបានបទពិសោធន៍ការងារយ៉ាងច្រើនដូចជា អ្នកបក ប្រែភាសា រដ្ឋបាល អ្នកគ្រប់គ្រងគំរោង និងជាអ្នកប្រឹក្សាយោបល់ក្នុងស្រុក ដែលមានទំនាក់ទំនងជាមួយនិងមន្ត្រីគ្រប់លំដាប់ថ្នាក់ក្នុងក្រសួងគ្រប់ ខេត្ត-ក្រុង រួមជាមួយនឹងដៃគូអភិវឌ្ឍ អង្គការសហប្រជាជាតិ, IO, អង្គការក្រៅរដ្ឋាភិបាល, វិស័យឯកជនក្នុង ផ្នែកអភិវឌ្ឍផែនការថ្នាក់ជាតិ, ហិរញ្ញវត្ថុ ស្ថិតិ ការអប់រំ M&E, Health based UNTAC, WHO-Ministry of Health, and UN-Ministry of Planning.



លោក ព្រាប កណ្ដឹង
ជំនួយការនាយកប្រតិបត្តិ

លោក **ព្រាប កណ្ដឹង** បានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតផ្នែកហិរញ្ញវត្ថុ (Master of Business Specializing in Finance) ពីសាកលវិទ្យាល័យ Charles Sturt University នៃប្រទេសអូស្ត្រាលី និងបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រផ្នែកគណនេយ្យ នៅសាកលវិទ្យាល័យជាតិគ្រប់គ្រង។ លោកមានបទពិសោធន៍ការងារជាច្រើនឆ្នាំ ដែលពាក់ព័ន្ធទៅនឹងវិស័យធនាគារ និងហិរញ្ញវត្ថុ ការសិក្សា ក៏ដូចជាបទពិសោធន៍ការងារបានធ្វើអោយគាត់មានការអភិវឌ្ឍន៍ជាបន្តបន្ទាប់ នូវភាពរីកចំរើននៃអាជីពការងាររបស់គាត់។ មុនពេលគាត់ចូលរួមបំរើការងារជាមួយ **ហ្វូតាបា** លោកមានបទពិសោធន៍ការងារជាច្រើនពាក់ពន្ធ័ទៅនឹងការគ្រប់គ្រងគណនេយ្យ ប្រឹក្សាយោបល់ ផ្នែកគណនេយ្យ និងជានាយក នាយកដ្ឋានហិរញ្ញវត្ថុ និងគណនេយ្យ។ លោកបានចូលរួមជាមួយ **ហ្វូតាបា** នៅឆ្នាំ២០១៥ ដែលមានតួនាទីជានាយក នាយកដ្ឋានហិរញ្ញវត្ថុ។ នៅខែកក្កដា ឆ្នាំ២០១៦ លោកត្រូវបានតែងតាំងតួនាទីជា ជំនួយការនាយកប្រតិបត្តិ ដែលទទួលខុសត្រូវទៅលើនាយកដ្ឋានចំនួនបី ដូចជានាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានព័ត៌មានវិទ្យា និងនាយកដ្ឋានធនធានមនុស្ស & រដ្ឋបាល។



លោក អ៊ុំ ពិសិដ្ឋ
ជំនួយការនាយកប្រតិបត្តិ

លោក **អ៊ុំ ពិសិដ្ឋ** បានចាប់ផ្ដើមអាជីពការងាររបស់លោកជាមួយ **ហ្វូតាបា** នៅចុងឆ្នាំ២០១៥ ក្នុងតួនាទីជានាយក នាយកដ្ឋានឥណទាន បន្ទាប់មកនៅខែកក្កដា ឆ្នាំ២០១៦ លោកត្រូវបានតែងតាំងជាជំនួយការនាយកប្រតិបត្តិ ដែលត្រូវទទួលបន្ទុកគ្រប់គ្រង និងមើលការខុសត្រូវលើនាយកដ្ឋាន ចំនួនបី គឺនាយកដ្ឋានឥណទាន នាយកដ្ឋានប្រតិបត្តិការ និងនាយកដ្ឋានទីផ្សារ។ លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រផ្នែកគ្រប់គ្រងទូទៅ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ទទួលបានសញ្ញាប័ត្រភាសាអង់គ្លេសថ្នាក់ IEAP ពីសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ហើយបានចូលរួមវគ្គបណ្ដុះបណ្ដាល សន្និសិទ និងសិក្ខាសិលាជាច្រើន ដែលទាក់ទងទៅនឹងការវិវឌ្ឍន៍វិស័យអចលនទ្រព្យ ការគ្រប់គ្រងវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុជាដើម។ ចំពោះបទពិសោធន៍ការងារ លោកបានចំណាយពេលជាង ១0ឆ្នាំ ក្នុងវិស័យមីក្រូហិរញ្ញវត្ថុជាមួយនិងមុខតំណែងជាច្រើនដូចជា មន្ត្រីសាខា នាយកសាខា នាយកគ្រប់គ្រងតំបន់ នាយក នាយកដ្ឋានប្រតិបត្តិការ នាយក នាយកដ្ឋានទីផ្សារ និងទំនាក់ទំនងនាយកគ្រប់គ្រងឥណទាន នាយក នាយកដ្ឋានឥណទាន។ លោកក៏បានចំណាយពេលជាង បីឆ្នាំ បម្រើការងារនៅវិស័យទូរគមនាគមន៍ផងដែរ។



លោក ហួត សុខជា
នាយក នាយកដ្ឋានប្រតិបត្តិការ

លោក **ហួត សុខជា** ចាប់ផ្ដើមការងារជាមួយ **ហ្វូតាបា** ក្នុងតួនាទីជា នាយក នាយកដ្ឋានប្រតិបត្តិការនៅក្នុង ខែវិច្ឆិកា ឆ្នាំ២០១៥ ដែលលោកបានគ្រប់គ្រងនូវរាល់កិច្ចការ និងសកម្មភាពទាំងអស់នៅក្នុងការបង្កើតគោលនយោបាយនិង នីតិវិធីដែលទាក់ទងទៅនឹងផ្នែកបេឡា និងប្រតិបត្តិការសាខា។ លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រផ្នែកទីផ្សារ ហើយបានចូលរួមវគ្គបណ្ដុះបណ្ដាលសិក្ខាសាលា និងសន្និសិទជាច្រើនដែលទាក់ទងទៅនឹងការ គ្រប់គ្រង និងអភិវឌ្ឍន៍ ស្ថាប័នមីក្រូហិរញ្ញវត្ថុ។ លោកបានចំណាយពេលជាង ១៣ឆ្នាំ ជាមួយនិងបទពិសោធន៍ច្រើនផ្នែកដូចជា ផ្នែកប្រតិបត្តិការ ផ្នែកលក់ ផ្នែកទីផ្សារស្រាវជ្រាវ និងការអភិវឌ្ឍផលិតផល ខណៈពេលដែលលោកបានចំណាយពេល ៨ឆ្នាំចុងក្រោយ របស់លោកនៅក្នុងវិស័យ មីក្រូហិរញ្ញវត្ថុ ជាមួយស្ថាប័នដទៃទៀតមុនពេលដែលលោកបានចូលរួមជាមួយគ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី។



លោក លឹម សំបូរ
នាយក នាយកដ្ឋានធនធានមនុស្ស និងរដ្ឋបាល

លោក **លឹម សំបូរ** កើតនៅខែមិថុនា ឆ្នាំ១៩៨១ បានចូលរួមជាមួយគ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ចាប់ពីខែវិច្ឆិកា ឆ្នាំ២០១៥ ក្នុងមុខតំណែងជា នាយកនាយកដ្ឋានទីផ្សារ។ បន្ទាប់បម្រើការងាររយៈពេល២ឆ្នាំ លោកត្រូវបានផ្លាស់ប្ដូរមុខតំណែងជា នាយក នាយកដ្ឋានធនធានមនុស្ស និងរដ្ឋបាល នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៧ ដោយទទួលខុសត្រូវក្នុងការគ្រប់គ្រង រៀបចំចាត់ចែង និងបង្កើតគោលនយោបាយ នីតិវិធីការងារនានាពាក់ព័ន្ធនឹងកិច្ចការធនធានមនុស្ស និងផ្នែករដ្ឋបាល។ នៅមុនពេលចាប់ផ្ដើមអាជីពមួយនេះ លោកធ្លាប់មានបទពិសោធន៍ រយៈពេលជាង ១៤ឆ្នាំ បម្រើការងារជាមួយធនាគារធំៗចំនួនពីររួមមាន៖ ធនាគារបរទេសថ្នាក់តំបន់ និងធនាគារក្នុងស្រុកមួយ ដែលមានបណ្ដាញប្រតិបត្តិការធំជាងគេផងដែរ។ ជាមួយបទពិសោធន៍ក្នុងវិស័យធនាគារហិរញ្ញវត្ថុ លោកធ្លាប់បានទទួលខុសត្រូវមុខងារជាច្រើនដូចជា ប្រធានទំនាក់ទំនង ប្រធានផ្នែកឥណទានភតិសន្យា អនុប្រធានផ្នែកឥណទាន និងតួនាទីជាច្រើនទៀត ដែល លោកបានចំណាយពេលជាង១០ឆ្នាំ ចូលរួមក្នុងសកម្មភាព ជាច្រើននៃការលក់ជួរមុខ។ ដោយឡែក លោក លឹម សំបូរ បានបញ្ចប់ការ សិក្សាថ្នាក់បរិញ្ញាប័ត្រ ពីសាកលវិទ្យាល័យបៀលប្រាយ ផ្នែកហិរញ្ញវត្ថុ និងធនាគារ ក្នុងឆ្នាំ២០០៨។



លោក គង់ សាវ៉ាត់
នាយក នាយកដ្ឋានព័ត៌មានវិទ្យា

លោក **គង់ សាវ៉ាត់** កើតនៅឆ្នាំ ១៩៨៥។ លោកបានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិត ផ្នែកគ្រប់គ្រងអាជីវកម្ម (MBA) នៅសាកលវិទ្យាល័យជាតិគ្រប់គ្រង ក្នុងឆ្នាំ២០១១ បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រផ្នែកព័ត៌មានវិទ្យា នៅសាកលវិទ្យាល័យបៀលប្រាយ ក្នុងឆ្នាំ២០០៨ បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រផ្នែកអក្សរសាស្ត្រអង់គ្លេស នៅសាកលវិទ្យាល័យន័រតុន នៅដើមឆ្នាំ២០១៦។ ជាមួយនិងអតីតភាពការងារ លោកមានតួនាទីជាប្រធានគ្រប់គ្រងផ្នែកព័ត៌មានវិទ្យា នៃធនាគារពាណិជ្ជមួយនៅកម្ពុជា ដែលមានបទពិសោធជាង ៨ឆ្នាំ ក្នុងវិស័យធនាគារ ហើយលោកបានចូលបម្រើការងារនៅ **ហ្វូតាបា** ចាប់តាំងពីខែមករា ឆ្នាំ២០១៦ មក។ បច្ចុប្បន្នលោកមានតួនាទីជា នាយក នាយកដ្ឋានព័ត៌មានវិទ្យា។



**លោក ផុន សុធា**
**នាយក នាយកដ្ឋានឥណទាន**

លោក **ផុន សុធា** បានចូលបម្រើការងារនៅក្នុងគ្រឹះស្ថាន **ហ្វូតាបា** ចាប់ពីថ្ងៃទី០១ខែកក្កដា ឆ្នាំ២០១៧។ មុនពេលដែលគាត់ចូលបម្រើការងារនៅគ្រឹះស្ថាន **ហ្វូតាបា** លោកបានកាន់ការងារក្នុងតួនាទីជា នាយក នាយកដ្ឋានឥណទាន អស់រយៈពេល៧ឆ្នាំជាប់គ្នា ក្នុងវិស័យហិរញ្ញវត្ថុនៅកម្ពុជាក្នុងចន្លោះឆ្នាំ២០១០ ដល់ពាក់កណ្តាលឆ្នាំ២០១៧។ ហើយនៅចន្លោះពីឆ្នាំ២០០៤ រហូតដល់ចុងឆ្នាំ២០១០ លោកសុធា ជាបុគ្គលិករបស់គ្រឹះស្ថានខ្នាតមធ្យមមួយកន្លែង ដែលការងារដំបូងគាត់បានចូលបម្រើនៅទីនោះ គឺមាននាទីជាជំនួយការរដ្ឋបាល / ហិរញ្ញវត្ថុ គាត់ត្រូវបានតែងតាំងជាបន្តបន្ទាប់រហូតក្លាយជានាយកសាខាដ៏ឆ្នើម របស់គ្រឹះស្ថានមួយនេះផងដែរ។ បើនិយាយពីប្រវត្តិនៃការសិក្សា លោកបានបញ្ចប់ថ្នាក់ បរិញ្ញាប័ត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងការអភិវឌ្ឍន៍ នៅសាកលវិទ្យាល័យន័រតុន ក្នុងឆ្នាំ២០១១ និងបានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រផ្នែកគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា នៅសាកលវិទ្យាល័យជាតិគ្រប់គ្រងក្នុងឆ្នាំ២០០៤។ ក្នុងរយៈពេលជាង១៤ឆ្នាំកន្លងមកនេះ លោកបានចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាជាច្រើនទាំងក្នុងប្រទេស និងក្រៅប្រទេស ដែលពាក់ព័ន្ធនឹងវិស័យគ្រឹះស្ថានហិរញ្ញវត្ថុ ធនាគារ វិស័យអចលនទ្រព្យ វិស័យ ធានារ៉ាប់រង និងច្បាប់ការងារផ្សេងៗជាច្រើនទៀត។



**លោក ស ភារុំ**
**នាយករង នាយកដ្ឋានច្បាប់ និងប្រតិបត្តិតាម**

លោក **ស ភារុំ** បានចូលបម្រើការងារនៅក្នុងគ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ក្នុងតួនាទីជានាយករង នាយកដ្ឋានច្បាប់ និងប្រតិបត្តិតាម ចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៧។ មុនពេលគាត់ចូលបម្រើការងារនៅគ្រឹះស្ថាន **ហ្វូតាបា** លោកបានបម្រើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ចម្រើន ម៉ាយក្រូហ្វាយនែន ភីអិលស៊ី ក្នុងតួនាទីចុងក្រោយជាប្រធាននាយកដ្ឋាន គ្រប់គ្រងហានិភ័យ និងនីតិកម្ម ហើយគាត់បានចាប់ផ្តើមការងារក្នុងតួនាទីច្រើនជាមួយគ្រឹះស្ថាន ចម្រើន ដែលចាប់ផ្តើមពីខែកុម្ភៈ ឆ្នាំ២០០៩ ជាមន្ត្រីឥណទាន និងបានក្លាយជាមន្ត្រីសវនកម្មផ្ទៃក្នុងក្នុងខែកុម្ភៈ ឆ្នាំ២០១០។ ក្រោយមកគាត់ត្រូវបានតែងតាំងជាប្រធានសាខានៅខែវិច្ឆិកា ឆ្នាំ២០១០ និងប្តូរទៅជាមន្ត្រីប្រតិបត្តិតាមជាន់ខ្ពស់ ក្នុងខែមិថុនា ឆ្នាំ២០១២។ បន្តបន្ទាប់មកគាត់ក៏ត្រូវបានដំឡើងទៅជាប្រធានផ្នែកច្បាប់ និងប្រតិបត្តិតាម ក្នុងខែមិថុនា ឆ្នាំ២០១៣ និងជាប្រធាននាយកដ្ឋានច្បាប់ ក្នុងខែមករា ឆ្នាំ២០១៥ ហើយបានទទួលខុសត្រូវក្នុងតួនាទីចុងក្រោយជាប្រធាននាយកដ្ឋាន គ្រប់គ្រងហានិភ័យ និងនីតិកម្ម។ ហើយគាត់ក៏ធ្លាប់បម្រើការងារនៅសណ្ឋាគារ Feeling Home ជាអ្នកទទួលភ្ញៀវរយៈពេល ១ឆ្នាំ និងធ្វើការជាអ្នកស្ម័គ្រចិត្តជាមួយអង្គការទស្សនៈពិភពលោកនៅស្រុករយៈពេល ៤ឆ្នាំផងដែរ។ គាត់បានទទួលសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ នីតិសាស្រ្ត ផ្នែកនីតិឯកជន នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច និងបរិញ្ញាបត្រផ្នែកគណនេយ្យពីសាកលវិទ្យាល័យធនធានមនុស្ស។ ក្នុងតួនាទី និងការទទួលខុសត្រូវនោះ គាត់មានបទពិសោធន៍ក្នុងតួនាទីផ្សេងៗគ្នារយៈពេល ៩ឆ្នាំ ក្នុងវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ។




# សមិទ្ធផលអាជីវកម្ម

១. សមិទ្ធផលឥណទានតាមវិស័យ

២. សមិទ្ធផលឥណទានតាមផលិតផល

# សមិទ្ធផលឥណទានតាមវិស័យ

## ចំនួនគណនី

| ល.រ | វិស័យ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|
| ១ | កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ២ | ៦ | ១៤ |
| ២ | ជំនួញ និងពាណិជ្ជកម្ម | ៥៩ | ១០៥ | ១១១ |
| ៣ | សំណង់ និងទ្រព្យមិនអាចចល័តបាន | ៣៩ | ១៧ | ៧៧ |
| ៤ | ការដឹកជញ្ជូន | ១០ | ២២ | ៤២ |
| ៥ | សេវាកម្ម | ១២ | ១៤ | ១៥ |
| ៦ | ប្រើប្រាស់ក្នុងគ្រួសារ | ២១០ | ៤៦៤ | ៤៣៤ |
| ៧ | ប្រភេទផ្សេងៗទៀត | - | - | ៨៧ |
| | **សរុប :** | **៣៣២** | **៦២៨** | **៧៨០** |

## ផលប័ត្រឥណទាន

| ល.រ | វិស័យ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|
| ១ | កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ២៣.៦៦៦ | ៧១.៤០២ | ១៧៨.៥០៣ |
| ២ | ជំនួញ និងពាណិជ្ជកម្ម | ១.៤៥៧.២៩៨ | ២.១៣១.៩៨០ | ២.០៣៥.២២៣ |
| ៣ | សំណង់ និងទ្រព្យមិនអាចចល័តបាន | ៥៣១.៧៥៨ | ៣០១.៨២៩ | ១.៥២៨.២៤៤ |
| ៤ | ការដឹកជញ្ជូន | ១៧៤.៤៩១ | ៤៣៣.៧៦២ | ៦៩៥.៨៩៩ |
| ៥ | សេវាកម្ម | ២២០.៨០០ | ៣៥៧.៣៥៦ | ៣៥៦.៦៥៩ |
| ៦ | ប្រើប្រាស់ក្នុងគ្រួសារ | ៣.៩៣៩.២២៧ | ៧.៤០១.៣៣៨ | ៧.៥០៣.៨៥៥ |
| ៧ | ប្រភេទផ្សេងៗទៀត | - | - | ៥០៦.៤២៥ |
| | **សរុប :** | **៦.៣៤៧.២៤១** | **១០.៦៩៧.៦៦៨** | **១២.៨០៤.៨០៨** |

# សមិទ្ធផលឥណទានតាមផលិតផល

## ចំនួនគណនី

| ល.រ | ផលិតផល | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|
| ១ | ឥណទានអាជីវកម្ម | ៩៥ | ១៦៩ | ១៦៤ |
| ២ | ឥណទានប្រើប្រាស់ផ្ទាល់ខ្លួន | ១២៣ | ២៣៩ | ២៧៤ |
| ៣ | ឥណទានកសិកម្ម | ២ | ៩ | ១៥ |
| ៤ | ឥណទានគេហដ្ឋាន | ៨៨ | ១៦៣ | ២៤០ |
| ៥ | ឥណទានបុគ្គលិក | ២២ | ៣២ | ៥០ |
| ៦ | ឥណទានសិក្សា | ២ | ១៦ | ៦ |
| ៧ | ឥណទាននិយោជិត | - | - | ៣១ |
| | **សរុប :** | **៣៣២** | **៦២៨** | **៧៨០** |

## ផលប័ត្រឥណទាន

| ល.រ | ផលិតផល | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|
| ១ | ឥណទានអាជីវកម្ម | ២.១៧៨.១០៥ | ៣.៥៦២.៥៩១ | ៣.២៥៤.១៦៤ |
| ២ | ឥណទានប្រើប្រាស់ផ្ទាល់ខ្លួន | ១.៦៧៥.៣៩៥ | ២.៩១៥.៥៦៩ | ៣.៣៣៦.៤៣៣ |
| ៣ | ឥណទានកសិកម្ម | ៨.៦៤៩ | ៩៣.១៥៥ | ១៨៥.៩៣៨ |
| ៤ | ឥណទានគេហដ្ឋាន | ២.៣០៩.៥១១ | ៣.៨៨៨.៨៧១ | ៥.៥៨១.៩១៧ |
| ៥ | ឥណទានបុគ្គលិក | ១៧៤.១៨១ | ២២៩.៣៥៩ | ៣៧៨.៨៩៦ |
| ៦ | ឥណទានសិក្សា | ១.៤០០ | ៨.១២៣ | ២.៩៨៦ |
| ៧ | ឥណទាននិយោជិត | - | - | ៦៤.៤៧៤ |
| | **សរុប :** | **៦.៣៤៧.២៤១** | **១០.៦៩៧.៦៦៨** | **១២.៨០៤.៨០៨** |





# ផលិតផល ហូតាបា

១. ឥណទានអាជីវកម្ម
២. ឥណទានគេហដ្ឋាន
៣. ឥណទានប្រើប្រាស់ផ្ទាល់ខ្លួន
៤. ឥណទានកសិកម្ម
៥. ឥណទានសិក្សា
៦. ឥណទានបុគ្គលិក
៧. ឥណទាននិយោជិត

# ផលិតផល និងសេវាកម្ម

គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បានបង្កើតឡើង និងដាក់ឲ្យដំណើរការនូវផលិតផល និងសេវាកម្មជាច្រើនសម្រាប់ផ្តល់ជូនអតិថិជនទៅតាមតម្រូវការប្រើប្រាស់ និងលំហូរសាច់ប្រាក់ជាក់ស្តែងរបស់ពួកគាត់ ដែលអាចធ្វើការជ្រើសរើសនូវជម្រើសដ៏សមស្របណាមួយដូចខាងក្រោម៖





## ឥណទានអាជីវកម្ម

អតិថិជនគោលដៅ :
អតិថិជនទូទៅ ដែលមានតម្រូវការសាច់ប្រាក់សម្រាប់ចាប់ផ្តើម ឬ ពង្រីកអាជីវកម្ម ដើម្បីបង្កើនប្រាក់ចំណេញ។

ប្រភេទរូបិយប័ណ្ណ : ដុល្លារអាមេរិក

ទំហំឥណទាន : ៥០០ - ២០០.០០០

រយៈពេលអតិបរមា : ១០ ឆ្នាំ



## ឥណទានគេហដ្ឋាន

អតិថិជនគោលដៅ :
អតិថិជនដែលមានតម្រូវការទិញផ្ទះ ឬ សាងសង់ផ្ទះសម្រាប់ស្នាក់នៅ និងប្រកបរបរអាជីវកម្ម។

ប្រភេទរូបិយប័ណ្ណ : ដុល្លារអាមេរិក

ទំហំឥណទាន : ៥០០ - ២០០.០០០

រយៈពេលអតិបរមា : ១០ ឆ្នាំ



## ឥណទានសម្រាប់ប្រើប្រាស់

អតិថិជនគោលដៅ :
អតិថិជនទូទៅ ដែលមានតម្រូវការសាច់ប្រាក់ ដើម្បីទិញឧបករណ៍សម្ភារៈផ្សេងៗ សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន។

- ប្រភេទរូបិយប័ណ្ណ : ដុល្លារអាមេរិក
- ទំហំឥណទាន : ៥០០ - ២០០.០០០
- រយៈពេលអតិបរមា : ១០ ឆ្នាំ



## ឥណទានកសិកម្ម

អតិថិជនគោលដៅ :
អតិថិជនដែលមានមុខរបរកសិកម្ម ហើយត្រូវការសាច់ប្រាក់បន្ថែម ដើម្បីវិនិយោគ បម្រើការឲ្យផ្នែកកសិកម្មរបស់ខ្លួន។

- ប្រភេទរូបិយប័ណ្ណ : ដុល្លារអាមេរិក
- ទំហំឥណទាន : ៥០០ - ២០០.០០០
- រយៈពេលអតិបរមា : ១០ ឆ្នាំ



## ឥណទានសិក្សា

អតិថិជនគោលដៅ៖
សម្រាប់អាណាព្យាបាល ឬ សិស្ស - និស្សិត ដែលខ្វះខាតផ្នែកហិរញ្ញវត្ថុ សម្រាប់បង់ថ្លៃសិក្សា។

ប្រភេទរូបិយប័ណ្ណ ៖ ដុល្លារអាមេរិក

ទំហំឥណទាន ៖ ៣០០ - ១.០០០

រយៈពេលអតិបរមា ៖ ១ ឆ្នាំ



## ឥណទានបុគ្គលិក

អតិថិជនគោលដៅ៖
សម្រាប់តែបុគ្គលិក **ហ្វូតាបា** តែប៉ុណ្ណោះ ដែលត្រូវការសាច់ប្រាក់ ដើម្បីគាំទ្រដល់ការរស់នៅប្រចាំថ្ងៃ។

ប្រភេទរូបិយប័ណ្ណ ៖ ប្រាក់រៀល ឬដុល្លារ

ទំហំឥណទាន ៖ ២៤ ដង ឬ ៤៨ ដង នៃប្រាក់ខែមូលដ្ឋាន

រយៈពេលអតិបរមា ៖ ១៥ ឆ្នាំ



## ឥណទាននិយោជិត

អតិថិជនគោលដៅ :
សម្រាប់បុគ្គលទូទៅដែលមានបំណង ចង់ទិញម៉ូតូ សម្ភារៈប្រើប្រាស់ រៀបការ និងផ្សេងៗ តែក្នុងលក្ខខណ្ឌស្របច្បាប់។

ប្រភេទរូបិយប័ណ្ណ : ប្រាក់រៀល ឬដុល្លារ

ទំហំឥណទាន : ២០.០០០.០០០ រៀល ឬ ៥.០០០ដុល្លារ

រយៈពេលអតិបរមា : ២ ឆ្នាំ

| លក្ខណៈសម្បត្តិរបស់អ្នកខ្ចី | ឯកសារតម្រូវ |
|---|---|
| - ជានីតិជនមានអាយុចាប់ពី ១៨ឆ្នាំ ទៅ ៦៥ឆ្នាំ<br>- មានទីលំនៅអចិន្ត្រៃយ៍ ស្ថិតក្នុងតំបន់ប្រតិបត្តិការរបស់ **ហ្វូតាបា** ។<br>- មានប្រវត្តិល្អនៅក្នុងសង្គម<br>- មានមុខរបរ ឬ អាជីវកម្មស្របច្បាប់<br>- មានទ្រព្យធានាត្រឹមត្រូវ | - អត្តសញ្ញាណប័ណ្ណ ឬ សៀវភៅគ្រួសារ ឬ សៀវភៅស្នាក់នៅ ឬ សំបុត្រកំណើត ឬ លិខិតឆ្លងដែន ... ។ល។<br>- ឯកសារទ្រព្យធានា (ប្លង់រឹង ឬ ប្លង់ទន់)<br>- ឯកសារផ្សេងៗ ពាក់ព័ន្ធនឹងប្រភពចំណូល |



# ការអភិវឌ្ឍន៍បុគ្គលិក

១. ការបណ្ដុះបណ្ដាល និងអភិវឌ្ឍបុគ្គលិក

២. ការចូលរួមវគ្គសិក្ខាសាលានៅខាងក្រៅ

# ការបណ្ដុះបណ្ដាល និងអភិវឌ្ឍបុគ្គលិក

ធនធានមនុស្សប្រកបដោយសក្ដានុពល និងមានចំណេះជំនាញច្បាស់លាស់ បានរួមចំណែកយ៉ាងសកម្មក្នុងការពង្រីកសកម្មភាពសេវាកម្មជូនដល់អតិថិជន ក៏ដូចជាបានគាំទ្រដល់ប្រតិបត្តិការ និងការរីកលូតលាស់ឥតឈប់ឈរនៃអាជីវកម្មរបស់ **ហ្វូតាបា** ទាំងមូល។

គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បានដាក់ចេញនូវផែនការយុទ្ធសាស្ត្របណ្ដុះបណ្ដាលប្រចាំឆ្នាំ ក្នុងគោលដៅជុសខាត់បង្កើនការយល់ដឹង ពង្រឹងសមត្ថភាពប្រតិបត្តិករគ្រប់រូប ដើម្បីជំរុញការអនុវត្តភារៈកិច្ចប្រកបដោយប្រសិទ្ធភាពខ្ពស់។

ទន្ទឹមគ្នានេះដែរ នាយកដ្ឋានធនធានមនុស្ស និងរដ្ឋបាល ជាអ្នកដើរតួយ៉ាងសំខាន់ ដោយសហការណ៍ជាមួយនាយកដ្ឋាននីមួយៗ ធ្វើការរៀបចំបង្កើតវគ្គហ្វឹកហ្វឺនយ៉ាងទៀងទាត់ ជូនដល់បុគ្គលិកពាក់ព័ន្ធជាបន្តបន្ទាប់។

ជាក់ស្ដែង **ហ្វូតាបា** បានផ្ដល់ឱ្យបុគ្គលិកនូវការបណ្ដុះបណ្ដាលជាច្រើនទៅតាមមុខងារ តួនាទីនីមួយៗ ដែលរួមមានការបណ្ដុះបណ្ដាលខាងក្នុង និងការចាត់បញ្ជូនបុគ្គលិកឱ្យចូលរួមវគ្គបណ្ដុះបណ្ដាលខាងក្រៅផងដែរ។

## ការបណ្ដុះបណ្ដាលខាងក្នុង

ក្នុងឆ្នាំ២០១៨ **ហ្វូតាបា** សម្រេចបាននូវការរៀបចំវគ្គបណ្ដុះបណ្ដាលខាងក្នុង ជូនបុគ្គលិកគ្រប់ផ្នែកជាបន្តបន្ទាប់មានចំនួនសរុប ០៩លើក។









សកម្មភាពបណ្ដុះបណ្ដាលបុគ្គលិកខាងក្នុង

## ការរៀបចំវគ្គសិក្ខាសាលាប្រចាំឆ្នាំរបស់គ្រឹះស្ថាន ហ្វូតាបា

ជាថ្មីម្តងទៀតកាលពីថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៨ គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បាន ប្រារព្ធពិធីសិក្ខាសាលាប្រចាំឆ្នាំរបស់ខ្លួនប្រកបដោយជោគជ័យក្រោមប្រធានបទ «សិក្ខាសាលាបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៨ និង ទិសដៅសម្រាប់អនុវត្តឆ្នាំបន្តបន្ទាប់» ។

គួរបញ្ជាក់ផងដែរថា នេះគឺជាសិក្ខាសាលាលើកទីពីរដែល **ហ្វូតាបា** បានរៀបចំឡើងក្នុងគោលបំណងជួបជុំ ក៏ដូចជាជំរុញលើកទឹកចិត្តបុគ្គលិកដែលបានខិតខំបំពេញការងាររយៈពេលពេញមួយឆ្នាំ និងបង្កើតបរិយាកាសរីករាយចុងឆ្នាំផងដែរ។



សិក្ខាសាលាប្រចាំឆ្នាំ២០១៨

## ការបណ្តុះបណ្តាលខាងក្រៅ

ការស្រូបយកចំណេះដឹង ក៏ដូចជាព័ត៌មានថ្មីៗពីខាងក្រៅ គឺជាតម្រូវការមិនអាចខ្វះបានក្នុងការរួមចំណែកអភិវឌ្ឍ ធនធានមនុស្សប្រកបដោយប្រសិទ្ធភាព។

ក្នុងន័យនេះ **ហ្វូតាបា** ក៏បានចាត់បញ្ជូនបុគ្គលិកជំនាញទៅចូលរួមវគ្គបណ្តុះបណ្តាលនានា នៅខាងក្រៅផងដែរ។ ជាក់ស្តែងក្នុងឆ្នាំ២០១៨ **ហ្វូតាបា** បានចាត់បញ្ជូនបុគ្គលិកជំនាញឱ្យចូលរួមវគ្គបណ្តុះបណ្តាលខាងក្រៅ ជាបន្តបន្ទាប់មានចំនួនសរុប ០៥លើក។



សកម្មភាពបណ្តុះបណ្តាលបុគ្គលិកខាងក្រៅ

# ការចូលរួមវគ្គសិក្ខាសាលានៅខាងក្រៅ

ការចូលរួមវគ្គសិក្ខាសាលានានានៅខាងក្រៅ បាននាំមកនូវបទពិសោធន៍ និងចំណេះដឹងទាន់សម័យ ដោយរួមចំណែកផងដែរដល់ការរៀបចំ និងការប្រតិបត្តិបានត្រឹមត្រូវស្របតាមបរិបទថ្មីៗនៃទីផ្សារហិរញ្ញវត្ថុនៅកម្ពុជា។

ជាមួយគ្នានេះថ្នាក់ដឹកនាំរបស់ **ហ្វូតាបា** តែងតែមានវត្តមាននៅក្នុងវគ្គសិក្ខាសាលានានាស្តីពីវិស័យហិរញ្ញវត្ថុនៅកម្ពុជា។




សកម្មភាពចូលរួមសិក្ខាសាលាខាងក្រៅ




# ការគ្រប់គ្រងហានិភ័យ

១. ការគ្រប់គ្រងហានិភ័យ និងការប្រតិបត្តិតាម

២. ការត្រួតពិនិត្យផ្ទៃក្នុង

# ការគ្រប់គ្រងហានិភ័យ និងការប្រតិបត្តិតាម

ការត្រួតពិនិត្យខាងក្រៅក៏ជាផ្នែកមួយនៃការត្រួតពិនិត្យលើប្រតិបត្តិការរបស់ស្ថាប័នមានដូចជា អ្នកពិគ្រោះយោបល់ក្រុមហ៊ុនសវនកម្មឯករាជ្យ និងនិយ័តករ ដែលអាចបង្ហាញឱ្យឃើញថា គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី មានចំណុចខ្វះខាត និងកំណត់ច្បាស់ពីតម្រូវការរបស់ស្ថាប័នដែលត្រូវកែលម្អ។ ការគ្រប់គ្រងការប្រតិបត្តិតាម បានបន្តពង្រឹងការអនុវត្តផ្ទៃក្នុងរបស់គ្រឹះស្ថាន **ហ្វូតាបា** ដោយផ្តោតលើការអនុលោមតាមច្បាប់នានានៃការផ្តល់អាជ្ញាប័ណ្ណរបស់ធនាគារជាតិនៃកម្ពុជា និងការចុះបញ្ជីជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីធានាបាននូវការពង្រីកអាជីវកម្ម និងប្រតិបត្តិការរបស់គ្រឹះស្ថាន **ហ្វូតាបា** ប្រកបដោយភាពពេញលេញស្របតាមច្បាប់ បទបញ្ជាផ្ទៃក្នុង និងបទប្បញ្ញត្តិនានានៅក្នុងវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ។ សមាជិកក្រុមប្រឹក្សា បានសម្រេចបង្កើតឱ្យមាននាយកដ្ឋានច្បាប់ និងប្រតិបត្តិតាម ដែលទទួលខុសត្រូវ ដោយនាយករងនាយកដ្ឋានច្បាប់ និងប្រតិបត្តិតាម គឺដើម្បីធានាថាការគ្រប់គ្រងហានិភ័យនៃការប្រតិបត្តិតាមរបស់គ្រឹះស្ថាន **ហ្វូតាបា** មានភាពច្បាស់លាស់ដោយត្រូវត្រួតពិនិត្យលើការគ្រប់គ្រងផ្ទៃក្នុងដើម្បីកំណត់អត្តសញ្ញាណ និងវាយតម្លៃលើហានិភ័យទាំងខាងក្នុង និងក្រៅដែលអាចមានការគំរាមកំហែង ឬផលប៉ះពាល់ដល់ប្រតិបត្តិការរបស់គ្រឹះស្ថាន **ហ្វូតាបា** និងធានាថាការអនុវត្ត និងនីតិវិធីត្រូវបានអនុវត្តបានពេញលេញស្របតាមច្បាប់ និងបទប្បញ្ញត្តិនានា។ ក្រៅពីនេះលោកក៏ទទួលខុសត្រូវ ក្នុងការត្រួតពិនិត្យការអនុលោមទៅតាមគោលការណ៍ផ្ទៃក្នុង នីតិវិធី និងគោលការណ៍ណែនាំនានា ទាក់ទងនឹងការអនុវត្តច្បាប់របស់គ្រឹះស្ថានរួមមានការធ្វើការសាកល្បង និងត្រួតពិនិត្យលើមុខងារតួនាទីឱ្យមានប្រសិទ្ធភាព និងការប្រកាន់ខ្ជាប់នូវការអនុវត្តន៍លើគោលការណ៍ដែលមានស្រាប់ ជាមួយនឹងបញ្ហានានាទាំងខាងក្នុង និងក្រៅពាក់ព័ន្ធនឹងការប្រតិបត្តិតាម និងការគ្រប់គ្រងហានិភ័យនៃការប្រតិបត្តិតាម។ ក្នុងគោលដៅវាស់វែង និងត្រួតពិនិត្យលើសមត្ថភាព និងបទពិសោធន៍ការងាររបស់អ្នកទទួលខុសត្រូវផ្នែកប្រតិបត្តិតាម បានទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៨។ បន្ថែមលើនោះទៀត នាយកដ្ឋានច្បាប់ និងប្រតិបត្តិតាម ត្រូវទទួលខុសត្រូវត្រួតពិនិត្យលើការងារប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលត្រូវរាយការណ៍ និងសហការប្រតិបត្តិការជាមួយនាយកដ្ឋានស៊ើបការណ៍ហិរញ្ញវត្ថុ របស់ធនាគារជាតិនៃកម្ពុជាផងដែរ។

នាយករងនាយកដ្ឋានច្បាប់ និងប្រតិបត្តិតាម នឹងស្នើឱ្យមានជាការប្រជុំប្រចាំត្រីមាស ដើម្បីពិភាក្សាអំពីរបាយការណ៍នៃការប្រតិបត្តិតាមជាមួយគ្រប់នាយកដ្ឋាន ឬគណៈគ្រប់គ្រង និងពិនិត្យឡើងវិញនូវភាពគ្រប់គ្រាន់ និងភាពពេញលេញនៃការវិភាគហានិភ័យប្រតិបត្តិតាម។ រាល់ហានិភ័យប្រតិបត្តិតាមសំខាន់ៗត្រូវបានបង្ហាញ និងរាយការណ៍ទៅក្រុមប្រឹក្សាភិបាល ដើម្បីជាអនុសាសន៍ក្នុងការប្រតិបត្តិតាម និងដោះស្រាយឱ្យបានទាន់ពេលវេលា។

# សវនកម្មផ្ទៃក្នុង

សវនកម្មផ្ទៃក្នុង ត្រូវតែជាផ្នែកមួយឯករាជ្យក្នុងការត្រួតពិនិត្យ និងរាយការណ៍លើអនុវត្តទូទៅរបស់ស្ថាប័ន។ ផ្នែកសវនកម្មផ្ទៃក្នុងរបស់គ្រឹះស្ថាន **ហ្វូតាបា** ត្រូវបានបង្កើតឡើងនៅខែកក្កដា ឆ្នាំ២០១៧ ទទួលខុសត្រូវដោយមន្ត្រីសវនករផ្ទៃក្នុងជាន់ខ្ពស់ ហើយមន្ត្រីសវនករផ្ទៃក្នុងជាន់ខ្ពស់បានទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជានៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៨។ មន្ត្រីសវនករផ្ទៃក្នុងជាន់ខ្ពស់ នឹងទទួលខុសត្រូវក្នុងការធ្វើសវនកម្មផ្ទៃក្នុង និងប្រតិបត្តិការត្រួតពិនិត្យនានា នៅក្នុងគ្រឹះស្ថាន **ហ្វូតាបា** ដោយត្រូវអនុវត្តតាមផែនការសវនកម្ម បច្ចុប្បន្នភាពកម្មវិធីសវនកម្ម និងការបណ្តុះបណ្តាលបុគ្គលិក ដែលជាតម្រូវការចាំបាច់ដើម្បីបង្កើនគុណភាពសវនកម្មរបស់ខ្លួន។ តាមគោលការណ៍ និងផែនការរបស់សវនកម្មផ្ទៃក្នុងយ៉ាងហោចណាស់ ១ដងក្នុង១ឆ្នាំ ត្រូវចុះធ្វើសវនកម្មនៅការិយាល័យសាខា និងនាយកដ្ឋាននីមួយៗ។ ផ្នែកសវនកម្មផ្ទៃក្នុងត្រូវត្រួតពិនិត្យរាល់ប្រតិបត្តិការរបស់គ្រឹះស្ថាន **ហ្វូតាបា** និងរាយការណ៍ដោយឯករាជ្យ និងដោយផ្ទាល់ទៅក្រុមប្រឹក្សាភិបាល។ ជាក់ស្តែងនៅក្នុងឆ្នាំ២០១៨ សវនកម្មផ្ទៃក្នុងក៏បានរាយការណ៍នូវរបាយការណ៍សវនកម្មផ្ទៃក្នុងប្រចាំត្រីមាសរបស់ខ្លួនទៅសមាជិកក្រុមប្រឹក្សាភិបាលពីការអនុវត្តការងារ និងកំហុសឆ្គងនានានៃប្រតិបត្តិការគ្រឹះស្ថាន ក្រោមការគ្រប់គ្រងរបស់គណៈគ្រប់គ្រង នាយកដ្ឋាន និងការិយាល័យសាខានីមួយៗ។

ផែនការសវនកម្ម និងកម្មវិធីសវនកម្មត្រូវបានត្រួតពិនិត្យ និងអនុម័តដោយប្រធានក្រុមប្រឹក្សាភិបាល។ សកម្មភាពនៃផ្នែកសវនកម្មផ្ទៃក្នុង គឺដើម្បីធានានូវប្រសិទ្ធភាព និងប្រសិទ្ធផលនៃការងារសវនកម្មផ្ទៃក្នុង ការគ្រប់គ្រងផ្ទៃក្នុង ភាពគ្រប់គ្រាន់នៃរបាយការណ៍ និងការអនុលោមតាមគោលការណ៍ នីតិវិធី គោលការណ៍ណែនាំ និងបញ្ញត្តិនានា។ ដើម្បីការអនុវត្តតាមផែនការ និងប្រព័ន្ធត្រួតពិនិត្យមានភាពល្អប្រសើរ មន្ត្រីសវនកម្មផ្ទៃក្នុងជាន់ខ្ពស់ ត្រូវផ្តោតលើបញ្ហាជាយុទ្ធសាស្ត្រ មានការអភិវឌ្ឍន៍កម្មវិធី និងផែនការសវនកម្ម ការកែលម្អ ឬបច្ចុប្បន្នភាពលើគោលការណ៍សវនកម្ម និងការផ្តល់ប្រឹក្សាដល់គណៈគ្រប់គ្រងលើការគ្រប់គ្រងផ្ទៃក្នុងជាដើម។ សវនកម្មផ្ទៃក្នុងក៏ត្រូវមានផែនការច្បាស់លាស់ក្នុងការតាមដានលើការកែតម្រូវនូវកំហុសឆ្គង និងចំណុចខ្វះខាតនានាដែលបានរកឃើញផងដែរ។


www
$
Plan
Do
Check
Act
SUCCESS
Cloud
TEAM




# របាយការណ៍ សវនកម្មឯករាជ្យ

១. របាយការណ៍របស់ក្រុមប្រឹក្សាភិបាល
២. របាយការណ៍របស់សវនករឯករាជ្យ
៣. តារាងតុល្យការ
៤. របាយការណ៍លទ្ធផល
៥. របាយការណ៍បម្រែបម្រួលមូលធន
៦. របាយការណ៍លំហូរសាច់ប្រាក់

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល មានក្ដីសោមនស្សរីករាយធ្វើការបង្ហាញជូននូវរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល និងរបាយការណ៍ហិរញ្ញវត្ថុរបស់ **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ហៅកាត់ថា ("ក្រុមហ៊ុន") ដែលបានធ្វើសវនកម្មរួច សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៨។

## សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺផ្ដល់សេវាកម្មមីក្រូហិរញ្ញវត្ថុដែលមាននិរន្តរភាពជូនសហគ្រាសធុនតូច និងមធ្យម និងគ្រួសារ ដែលមានប្រាក់ចំណូលទាបនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៨ មានដូចខាងក្រោម៖

| | ៣១ ធ្នូ ២០១៨ | | ៣១ ធ្នូ ២០១៧ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ 5) |
| ប្រាក់ចំណេញមុនដកពន្ធ | ៥៣១.៦៦៦ | ២.១៣៦.២៣៣ | ១៤៧.២៧៣ | ៥៩៤.៥៤១ |
| ចំណាយពន្ធលើប្រាក់ចំណេញ | (៧៧.១៤៦) | (៣០៩.៩៧១) | (១២.៧៥៥) | (៥១.៤៩២) |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | ៤៥៤.៥២០ | ១.៨២៦.២៦២ | ១៣៤.៥១៨ | ៥៤៣.០៤៩ |

## ភាគលាភ

ក្រុមហ៊ុនពុំបានប្រកាស ឬបង់ភាគលាភ និងក្រុមប្រឹក្សាភិបាលមិនបានផ្ដល់អនុសាសន៍ ក្នុងការបែងចែកភាគលាភ ដែលត្រូវបង់ក្នុងការិយបរិច្ឆេទនេះទេ ។

## ដើមទុន

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ដើមទុនចុះបញ្ជីរបស់ក្រុមហ៊ុនមានចំនួន ៧.000.000 ដុល្លារអាមេរិក ដោយបោះផ្សាយភាគហ៊ុនចំនួន ៧.000 ភាគហ៊ុន ក្នុងតម្លៃ ១.000 ដុល្លារអាមេរិកក្នុងមួយភាគហ៊ុន (២០១៧: ៧.000.000 ដុល្លារអាមេរិក)។

ក្រុមហ៊ុន ពុំមានកិច្ចសន្យាផ្ដល់ភាគហ៊ុនមិនទាន់បោះផ្សាយ និងមិនមានភាគហ៊ុនក្រោមកិច្ចសន្យាផ្ដល់សិទ្ធិជាភាគហ៊ុននៃក្រុមហ៊ុននាចុងការិយបរិច្ឆេទនេះទេ ។

## ឥណទានអាក្រក់ និងជាប់សង្ស័យ

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាល

បានចាត់វិធានការសមស្រប ដើម្បីបញ្ជាក់ថាវិធានការទាក់ទងទៅនឹងការលុបបំបាត់ចោលឥណទានអាក្រក់ និងការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យត្រូវបានធ្វើឡើង ហើយក្រុមប្រឹក្សាភិបាលជឿជាក់ថា រាល់ឥណទានដែលបានដឹងថាមិនអាចទារបានត្រូវបានលុបបំបាត់ចោល ហើយសំវិធានធនត្រូវបានធ្វើឡើងយ៉ាងគ្រប់គ្រាន់ សម្រាប់ឥណទានដែលជាប់សង្ស័យ ។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយដែលនាំឲ្យឥណទានអាក្រក់ ដែលបានជំរះចេញពីបញ្ជី ឬចំនួនសំវិធានធនជាប់សង្ស័យក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មានតម្លៃមិនគ្រប់គ្រាន់ជាសារវន្តនោះទេ ។

## ទ្រព្យសកម្មចរន្ត

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការ ដែលមានមូលដ្ឋានសមរម្យ ដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្មចរន្តទាំងអស់ដែលបានកត់ត្រានៅក្នុងបញ្ជី គណនេយ្យរបស់ក្រុមហ៊ុន ហើយដែលទំនងជាមិនអាចទទួលស្គាល់បាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ត្រូវបានកាត់បន្ថយឲ្យនៅស្មើនឹងតម្លៃដែលគិតថានឹងអាចប្រមូលបានជាក់ស្តែង ។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងធ្វើឲ្យប៉ះពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្មចរន្តនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនថាមានភាពមិនត្រឹមត្រូវនោះទេ ។

## វិធីសាស្ត្រកំណត់តម្លៃ

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើង ដែលនឹងធ្វើឲ្យប៉ះពាល់ដល់ការអនុវត្តវិធីសាស្ត្រដែលមានកន្លងមកក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ថាមានភាពមិនត្រឹមត្រូវ និងមិនសមស្របនោះទេ ។

## បំណុលយថាហេតុ និងបំណុលផ្សេងៗទៀត

នាថ្ងៃចេញរបាយការណ៍នេះ ពុំមាន៖

(១) ការដាក់បញ្ចាំទ្រព្យសកម្មណាមួយរបស់ក្រុមហ៊ុន ដែលកើតមានឡើងចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទក្នុង ការធានាចំពោះបំណុលរបស់បុគ្គលណាមួយឡើយ ក្រៅអំពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ ។

(២) បំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះក្រុមហ៊ុន ចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទមក ក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ក្រុមហ៊ុន ។

ក្រុមប្រឹក្សាភិបាលមានមតិថា ពុំមានបំណុលយថាភាព ឬបំណុលផ្សេងៗទៀតរបស់ក្រុមហ៊ុន ដែលត្រូវសង ឬ អាចនឹងត្រូវសងក្នុងរយៈពេល ១២ខែ បន្ទាប់ពីចុងការិយបរិច្ឆេទនេះ ដែលនឹងធ្វើឲ្យមានផលប៉ះពាល់ ឬអាចនឹងប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន ដូចដែលបានកំណត់ និងនៅពេលដែលដល់ថ្ងៃកំណត់ ។

## ការផ្លាស់ប្តូរនៃហេតុការណ៍

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលមិនបានរៀករៀបនៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលនឹងបណ្តាលឲ្យមានតួលេខនៃចំនួនណាមួយ ដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ មានភាពមិនត្រឹមត្រូវនោះទេ ។

## ប្រតិបត្តិការមិនប្រក្រតី

ក្រុមប្រឹក្សាភិបាល មានមតិថាលទ្ធផលនៃការធ្វើប្រតិបត្តិការរបស់ក្រុមហ៊ុន ក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះមិនមានផលប៉ះពាល់ជាសារវន្តដោយសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះទេ ។

ក្រុមប្រឹក្សាភិបាលក៏មានមតិផងដែរថា នៅក្នុងចន្លោះពេលចាប់ពីថ្ងៃចុងការិយបរិច្ឆេទដល់ថ្ងៃចេញរបាយការណ៍នេះ ពុំមានចំណាត់ថ្នាក់សកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីកើតមានឡើងដែលអាចនាំឲ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទ ដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ ។

## ព្រឹត្តិការណ៍ក្រោយកាលបរិច្ឆេទរាយការណ៍

ពុំមានព្រឹត្តិការណ៍សារវន្តកើតឡើងក្រោយនាថ្ងៃចេញរបាយការណ៍នេះ ដែលតម្រូវឲ្យមានការលាតត្រដាង ឬនិយ័តភាព ក្រៅពីព្រឹត្តិការណ៍ដែលបានលាតត្រដាងរួចហើយនៅក្នុងកំណត់សំគាល់ដែលភ្ជាប់ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុ ។

## ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលដែលបានបម្រើការនៅក្នុងការិយបរិច្ឆេទ និងនាថ្ងៃចេញរបាយការណ៍នេះ រួមមាន៖

| | |
|---|---|
| • លោក ច្រឹក ផល្លី | ប្រធានក្រុមប្រឹក្សាភិបាល |
| • លោក Yosuke Sasaki | អភិបាល |
| • លោក Junichi Sasaki | អភិបាល |

## ចំណែកហ៊ុនរបស់ក្រុមប្រឹក្សាភិបាល

មិនមានសមាជិកក្រុមប្រឹក្សាភិបាលណា កាន់កាប់ ឬទទួលខុសត្រូវលើភាគហ៊ុនរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទ នេះទេ ។

ផលប្រយោជន៍ដោយប្រយោល របស់សមាជិកក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុននេះ ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុង និងនាចុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ពុំមានការរៀបចំណាមួយដែលមានក្រុមហ៊ុនជាគូភាគីមួយក្នុងគោលបំណងជួយដល់សមាជិកក្រុមប្រឹក្សាភិបាល ដើម្បីទទួលបាននូវអត្ថប្រយោជន៍ដោយមធ្យោបាយទិញយក ភាគហ៊ុន ឬលិខិតបំណុលពីក្រុមហ៊ុន ឬពីក្រុមហ៊ុនដទៃទៀតទេ ។

ចាប់តាំងពីដើមការិយបរិច្ឆេទហិរញ្ញវត្ថុ ពុំមានសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់បានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ដែលបានទទួលដូចបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ) តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយក្រុមហ៊ុន ឬដោយក្រុមហ៊ុនពាក់ព័ន្ធនឹងក្រុមហ៊ុនដែលសមាជិកក្រុមប្រឹក្សាភិបាលនោះជាសមាជិក ឬក៏ជាមួយក្រុមហ៊ុនដែលសមាជិកក្រុមប្រឹក្សាភិបាលនោះ មានផលប្រយោជនផ្នែកហិរញ្ញវត្ថុច្រើននោះទេ លើកលែងតែការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលមានភារៈធ្វើការអះអាងបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុបានរៀបចំឡើងយ៉ាងត្រឹមត្រូវ ដើម្បីចង្អុលបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ និងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨។ នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ក្រុមប្រឹក្សាភិបាលចាំបាច់ត្រូវ៖

**(ក)** អនុម័តនូវគោលនយោបាយគណនេយ្យដែលសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណ យ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តប្រកបដោយសង្គតិភាព ។

**(ខ)** អនុវត្តទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនឹង ការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើមានការផ្លាស់ប្តូរពីនេះ ដើម្បី បង្ហាញនូវភាពត្រឹមត្រូវ គឺត្រូវបង្ហាញពន្យល់ និងកំណត់បរិមាណឲ្យបានច្បាស់លាស់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

**(គ)** ត្រួតពិនិត្យប្រព័ន្ធដំណើរការរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងរក្សាទុកនូវបញ្ជីគណនេយ្យឲ្យបាន គ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឲ្យមានប្រសិទ្ធភាព ។

**(ឃ)** វាយតម្លៃនូវលទ្ធភាពរបស់ធនាគារក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មាន ប្រសិនបើពាក់ព័ន្ធ នូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាន និរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជីផ្អាកដំណើរការក្រុមហ៊ុន ឬ គ្មានជម្រើសសមរម្យ ដទៃទៀតក្រៅពីធ្វើបែបនេះ និង

**(ង)** ត្រួតពិនិត្យ និងដឹកនាំក្រុមហ៊ុនឲ្យមានប្រសិទ្ធភាពលើរាល់សេចក្ដីសម្រេចដែលមានសារៈសំខាន់ទាំងឡាយ ដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់ក្រុមហ៊ុន ហើយត្រូវប្រាកដថាកិច្ចការនេះ ត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

ក្រុមប្រឹក្សាភិបាលធានាអះអាងថាបានអនុវត្តនូវរាល់តម្រូវការ ដូចមានរាយការណ៍ខាងលើក្នុងការរៀបចំ របាយការណ៍ហិរញ្ញវត្ថុ ។

## ការអនុម័តរបាយការណ៍ហិរញ្ញវត្ថុ

យើងខ្ញុំ សូមធ្វើការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុដែលបានបង្ហាញនៅទំព័រទី១០ ដល់ទី៥១ ដែលជាមតិរបស់យើងខ្ញុំ បានបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

ចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សាភិបាល

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី
FUTABA MICROFINANCE PLC.
KINGDOM OF CAMBODIA

លោក ច្រឹក ផល្លី
ប្រធានក្រុមប្រឹក្សាភិបាល
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

លោក Junichi Sasaki
នាយកប្រតិបត្តិ

ថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៩

# របាយការណ៍របស់សវនករឯករាជ្យ

ជូនចំពោះភាគទុនិក

ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី

## មតិសវនកម្ម

យើងខ្ញុំ បានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ហៅកាត់ថា ("ក្រុមហ៊ុន") ដែលរួមមានតារាងតុល្យការនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ និងរបាយការណ៍លទ្ធផល របាយការណ៍ស្តីពីបម្រែបម្រួលមូលធន និងរបាយការណ៍លំហូរទឹកប្រាក់សម្រាប់ការិយបរិច្ឆេទ ដែលបានបញ្ចប់ និងកំណត់សំគាល់ដែលរួមមានគោលនយោបាយគណនេយ្យសំខាន់ៗ ព្រមទាំងព័ត៌មានពន្យល់ផ្សេងៗ ដែលបានបង្ហាញនៅទំព័រទី១០ ដល់ទី ៥១ ។

ជាមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុជាសារវន្ត បានបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់ របស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

## មូលដ្ឋាននៃមតិសវនកម្ម

យើងខ្ញុំ បានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា។ ការទទួលខុសត្រូវរបស់យើងខ្ញុំដែលស្របតាមស្តង់ដារទាំងនោះ ត្រូវបានរៀបរាប់បន្ថែមទៀតនៅក្នុងកថាខណ្ឌ ស្តីពី **ការទទួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ** ដែលមាននៅក្នុងរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំ មានភាពឯករាជ្យពីក្រុមហ៊ុន ដោយស្របទៅតាមតម្រូវការក្រម សីលធម៌វិជ្ជាជីវៈ ដែលពាក់ព័ន្ធនឹងសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយយើងខ្ញុំបានបំពេញនូវទំនួលខុសត្រូវលើក្រមសីលធម៌វិជ្ជាជីវៈ ស្របតាមតម្រូវការរបស់ស្តង់ដារទាំងនោះ។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំ ប្រមូលបានមានលក្ខណៈគ្រប់គ្រាន់ និងសមស្រប សម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ ។

## បញ្ហាផ្សេងទៀត

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ត្រូវបានធ្វើសវនកម្មដោយក្រុមហ៊ុនសវនករផ្សេង ដែលបានបញ្ចេញមតិសវនកម្ម នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៨ ថារបាយការណ៍ហិរញ្ញវត្ថុនោះ ជាសារវន្តមានភាពត្រឹមត្រូវ ។

## ព័ត៌មានផ្សេងៗ

អ្នកគ្រប់គ្រង ទទួលខុសត្រូវលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗ ដែលបានទទួលត្រឹមកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ គឺរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល ដែលបានបង្ហាញនៅទំព័រទី១ ដល់ទី៥ និងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុន ដែលរំពឹងថារួចរាល់បន្ទាប់ពីកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ ។

មតិសវនកម្មរបស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្តប់លើព័ត៌មានផ្សេងៗឡើយ ហើយ យើងខ្ញុំមិនធ្វើការផ្តល់នូវអំណះអំណាងណាមួយទៅលើព័ត៌មាននេះទេ ។

ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺត្រូវ

អានព័ត៌មានផ្សេងៗ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានភាពមិនស្របគ្នាជាសារវន្ត ជាមួយរបាយការណ៍ហិរញ្ញវត្ថុ ឬការយល់ដឹងរបស់យើងខ្ញុំនៅក្នុងការធ្វើសវនកម្ម ឬមានបង្ហាញនូវកំហុសឆ្គងជាសារវន្ត ។

ប្រសិនបើការអានព័ត៌មានផ្សេងៗ ដែលបានទទួលមុនកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ យើងខ្ញុំសន្និដ្ឋានថា មានកំហុសឆ្គងជាសារវន្តកើតឡើង យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំ ពុំមានអ្វីដែលត្រូវរាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានផ្សេងៗនេះទេ។

## ការទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុរបស់អ្នកគ្រប់គ្រង និងអ្នកទទួលខុសត្រូវលើអភិបាលកិច្ច

អ្នកគ្រប់គ្រង មានភារៈទទួលខុសត្រូវលើការរៀបចំ និងការបង្ហាញនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ហើយនិងទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលអ្នកគ្រប់គ្រងកំណត់ថាមានភាពចាំបាច់សម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុឲ្យជៀសផុតពីការបង្ហាញខុសជាសារវន្ត ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង ។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការវាយតម្លៃនូវលទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបន្តនិរន្តរភាពអាជីវកម្មទទួលខុសត្រូវលើការលាតត្រដាងព័ត៌មាន (ប្រសិនបើពាក់ព័ន្ធ) នូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាន និរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជីផ្អាកដំណើរការក្រុមហ៊ុន ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ ។

អ្នកទទួលខុសត្រូវលើអភិបាលកិច្ច មានភារៈទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការហិរញ្ញវត្ថុ របស់ក្រុមហ៊ុន ។

## ការទទួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលដៅរបស់យើងខ្ញុំ គឺផ្តល់នូវអំណះអំណាងសមហេតុផលថារបាយការណ៍ហិរញ្ញវត្ថុទាំងមូល មិនមានការបង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងផ្តល់នូវរបាយការណ៍របស់សវនករដែលរួមបញ្ចូលទាំងមតិសវនកម្មរបស់យើងខ្ញុំ។ អំណះអំណាងសមហេតុផល គឺជាអំណះអំណាងមានកម្រិតខ្ពស់មួយ ប៉ុន្តែវាមិនអាចធានាថា គ្រប់ពេលនៃការធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា អាចរកឃើញនូវកាបង្ហាញខុសជាសារវន្តដែលបានកើតឡើងនោះទេ។ ការបង្ហាញខុសជាសារវន្តអាចកើតឡើងដោយសារការក្លែងបន្លំ ឬកំហុសឆ្គង ហើយត្រូវបានចាត់ទុកថាជាសារវន្ត នៅពេលដែលការក្លែងបន្លំ ឬកំហុសឆ្គងតែមួយ ឬក៏រួមបញ្ចូលគ្នា មានផលប៉ះពាល់ដល់ការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ ដោយយោង លើរបាយការណ៍ហិរញ្ញវត្ថុនេះ។

ជាផ្នែកមួយនៃការធ្វើសវនកម្ម ដោយអនុលោមតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវការវិនិច្ឆ័យដែលប្រកបទៅដោយវិជ្ជាជីវៈ និងរក្សានូវមជ្ឈធាតុនិយម ក្នុងអំឡុងពេលសវនកម្ម។ យើងខ្ញុំក៏៖

- ធ្វើការកំណត់ និងវាយតម្លៃនូវហានិភ័យនៃការបង្ហាញខុសជាសារវន្តលើរបាយការណ៍ហិរញ្ញវត្ថុដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងទទួលខុសត្រូវលើការរៀបចំ និងការអនុវត្តនូវនីតិវិធីសវនកម្មដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងប្រមូលនូវភស្តុតាងដែលមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជា មូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។ ហានិភ័យដែលមិនអាច

រកឃើញនូវការបង្ហាញខុសជា សារវន្តដែលកើតឡើងដោយសារតែការក្លែងបន្លំ មានលក្ខណៈខ្ពស់ជាង ការបង្ហាញខុសកើតឡើងពីកំហុសឆ្គងដោយសារតែការក្លែងបន្លំ អាចរួមបញ្ចូលទាំងការឃុបឃិតគ្នា ការលួចបន្លំ ការលុបចោលដោយចេតនា ការបកស្រាយមិនពិត ឬមិនអនុវត្តតាមនីតិវិធីគ្រប់គ្រងផ្ទៃក្នុង។

- ទទួលបាននូវការយល់ដឹងអំពីការគ្រប់គ្រងផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្ម ក្នុងគោលបំណង ដើម្បីរៀបចំនូវនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុង គោលបំណង ដើម្បីបញ្ចេញមតិ លើប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុនឡើយ។
- ការវាយតម្លៃលើភាពសមស្រប នៃគោលនយោបាយគណនេយ្យដែលក្រុមហ៊ុន បានប្រើប្រាស់ និង ភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យសំខាន់ៗ ព្រមទាំងការលាតត្រដាងព័ត៌មានពាក់ព័ន្ធ ដែលបានធ្វើឡើងដោយអ្នកគ្រប់គ្រង ។
- ធ្វើការសន្និដ្ឋានលើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ របស់អ្នកគ្រប់គ្រង ហើយដោយផ្អែកទៅលើភស្តុតាងសវនកម្ម ដែលទទួលបានធ្វើការសន្និដ្ឋានថាតើភាពមិនច្បាស់លាស់សារវន្ត ពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចធ្វើឲ្យមានមន្ទិលជាសារវន្តលើលទ្ធភាព របស់ក្រុមហ៊ុន ដើម្បីបន្តនិរន្តរភាពអាជីវកម្ម។ ប្រសិនបើយើងខ្ញុំ ធ្វើការសន្និដ្ឋានថាមានអត្ថិភាពនៃ ភាពមិនប្រាកដប្រជាជាសារវន្ត យើងខ្ញុំចាំបាច់ត្រូវបញ្ចូល នៅក្នុងរបាយការណ៍របស់យើងខ្ញុំ ដើម្បី ទាញចំណាប់អារម្មណ៍លើការលាតត្រដាង ព័ត៌មានពាក់ព័ន្ធនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិន បើការលាតត្រដាង ព័ត៌មានមានលក្ខណៈមិនគ្រប់គ្រាន់  យើងខ្ញុំចាំបាច់ត្រូវផ្តល់មតិសវនកម្មដែល មានបញ្ហា។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកតាមភស្តុតាងសវនកម្មដែលប្រមូលបានត្រឹមកាល បរិច្ឆេទនៃរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។ យ៉ាងណាក៏ដោយព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេល អនាគត អាចធ្វើឲ្យក្រុមហ៊ុនបញ្ឈប់និរន្តរភាពអាជីវកម្ម ។
- វាយតម្លៃលើការបង្ហាញនៃទម្រង់ និងខ្លឹមសារនៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ដែលរួមបញ្ចូលទាំងការ លាតត្រដាងព័ត៌មាន និងវាយតម្លៃថាតើរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ ពាក់ព័ន្ធក្នុងអត្ថន័យ ដែលអាចសម្រេចបាននូវការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ។

យើងខ្ញុំ ផ្តល់ព័ត៌មានជូនអ្នកទទួលខុសត្រូវលើអភិបាលកិច្ច ស្តីពីបញ្ហាផ្សេងទៀត វិសាលភាព និងពេល វេលា ដែលបានគ្រោងទុកសម្រាប់ការធ្វើសវនកម្ម និងការរកឃើញបញ្ហាជាសារវន្តផ្សេងទៀតដែល មានរួមបញ្ចូលទាំង ចំណុចខ្វះខាតនៃការគ្រប់គ្រងផ្ទៃក្នុងដែលបានរកឃើញក្នុងអំឡុងពេលធ្វើសវនកម្ម ។

តំណាងក្រុមហ៊ុន **ខេភីអឹមជី ខេមបូឌា ចំកាត់**




ង៉ែ ហ៊ុយ

Partner

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៩

# តារាងតុល្យការ

## គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨

| | កំណត់សំគាល់ | ៣១ ធ្នូ ២០១៨ ដុល្លារអាមេរិក (កំណត់សំគាល់ ៥) | ៣១ ធ្នូ ២០១៨ ពាន់រៀល | ៣១ ធ្នូ ២០១៧ ដុល្លារអាមេរិក | ៣១ ធ្នូ ២០១៧ ពាន់រៀល (កំណត់សំគាល់ ៥) |
|---|---|---|---|---|---|
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៦ | ២២.១៩០ | ៨៩.១៥៩ | ៨.៥៨៩ | ៣៤.៦៧៤ |
| ប្រាក់បញ្ញើ និងប្រាក់ដម្កល់នៅធនាគាជាតិនៃកម្ពុជា | ៧ | ៣៥០. ០៨១ | ១.៤០៦,៦២៥ | ៣៥១.២៨២ | ១.៤១៨,១២៥ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនានា | ៨ | ២៨៧.៥៩១ | ១.១៥៥.៥៤១ | ៤៨៥.៦០០ | ១.៩៦០.៣៦៧ |
| ឥណទានផ្តល់ដល់អតិថិជន | ៩ | ១២.៦៧៦.៧៦០ | ៥០.៩៣៥.២២២ | ១០.៦៩៧.៦៦៨ | ៤៣.១៨៦.៤៨៦ |
| ទ្រព្យសកម្មផ្សេងៗ | ១០ | ២១៦.៨៦៦ | ៨៧១.៣៦៨ | ១៧៩.៥៩៣ | ៧២៥.០១៧ |
| ទ្រព្យនិងបរិក្ខារ | ១១ | ១៩៤.៥៣៨ | ៧៨១.៦៥៤ | ៣២៣.៦៥៣ | ១.៣០៦.៥៨៧ |
| ទ្រព្យសកម្មអរូបី | ១២ | - | - | ៨.២៥០ | ៣៣.៣០៥ |
| ពន្ធពន្យារជាទ្រព្យសកម្ម | ២០ | ៣៦.២៤២ | ១៤៥.៦២០ | - | - |
| **សរុបទ្រព្យសកម្ម** | | **១៣.៧៨៤.២៦៨** | **៥៥.៣៨៥.១៨៩** | **១២.០៥៤.៦៣៥** | **៤៨.៦៦៤.៥៦១** |
| **បំណុល និងមូលធន** | | | | | |
| **បំណុល** | | | | | |
| បំណុលផ្សេងៗ | ១៣ | ៣៥៩.៤៨៣ | ១.៤៤៤.៤០៣ | ២៣៧.៦៦៦ | ៩៥៩.៤៦១ |
| បំណុលពន្ធលើប្រាក់ចំណេញ | ២០ | ៩៧.៣២២ | ៣៩១.០៤០ | ១.០២៦ | ៤.១៤២ |
| ប្រាក់កម្ចី | ១៤ | ៤.៩៤៦.៧៨២ | ១៩.៨៧៦.១៧០ | ៤.៣៧៩.៧៨២ | ១៧.៦៨១.១៨០ |
| បុរេប្រទានពីភាគទុនិក | ១៥ | ១.៣៩០.០០០ | ៥.៥៨៥.០២០ | ៩០០.០០០ | ៣.៦៣៣.៣០០ |
| **សរុបបំណុល** | | **៦.៧៩៣.៥៨៧** | **២៧.២៩៦.៦៣៣** | **៥.៥១៨.៤៧៤** | **២២.២៧៨.០៨៣** |
| **មូលធន** | | | | | |
| ដើមទុន | ១៦ | ៧.០០០.០០០ | ២៨.១២៦.០០០ | ៧.០០០.០០០ | ២៨.២៥៩.០០០ |
| ប្រាក់ខាតបង្គរ | | (៩.៣១៩) | (៣៧.៤៤៤) | (៤៦៣.៨៣៩) | (១.៨៧២.៥២២) |
| **សរុបមូលធន** | | **៦.៩៩០.៦៨១** | **២៨.០៨៨.៥៥៦** | **៦.៥៣៦.១៦១** | **២៦.៣៨៦.៤៧៨** |
| **សរុបបំណុល និងមូលធន** | | **១៣.៧៨៤.២៦៨** | **៥៥.៣៨៥.១៨៩** | **១២.០៥៤.៦៣៥** | **៤៨.៦៦៤.៥៦១** |

# របាយការណ៍លទ្ធផល

*សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨*

| | កំណត់សំគាល់ | ៣១ ធ្នូ ២០១៨ ដុល្លារអាមេរិក | ៣១ ធ្នូ ២០១៨ ពាន់រៀល (កំណត់សំគាល់ ៥) | ៣១ ធ្នូ ២០១៧ ដុល្លារអាមេរិក | ៣១ ធ្នូ ២០១៧ ពាន់រៀល (កំណត់សគាល់ ៥) |
|---|---|---|---|---|---|
| ចំណូលពីការប្រាក់ | ១៧ | ១.៥៩៦.៣៤៨ | ៦.៤១៤.១២៧ | ១.១៨២.២១៥ | ៤.៧៧២.៦០២ |
| ចំណាយការប្រាក់ | | (៧១.០១៨) | (២៨៥.៣៥០) | (៤១.១៦៥) | (១៦៦.១៨៣) |
| **ចំណូលពីការប្រាក់សុទ្ធ** | | **១.៥២៥.៣៣០** | **៦.១២៨.៧៧៧** | **១.១៤១.០៥០** | **៤.៦០៦.៤១៩** |
| ចំណូលពីប្រតិបត្តិការផ្សេងៗ | ១៨ | ១៦៥.៣១៤ | ៦៦៤.២៣១ | ៩៣.៧៦៧ | ៣៧៨.៥៣៧ |
| ចំណាយទូទៅ និងរដ្ឋបាល | ១៩ | (១.០៣០.៩៣០) | (៤.១៤២.២៧៨) | (១.០៨៧.៥៤៤) | (៤.៣៩០.៤១៥) |
| សំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យ | ៩ | (១២៨.០៤៨) | (៥១៤.៤៩៧) | - | - |
| ប្រាក់ចំណេញមុនដកពន្ធ | | ៥៣១.៦៦៦ | ២.១៣៦.២៣៣ | ១៤៧.២៧៣ | ៥៩៤.៥៤១ |
| ចំណាយពន្ធលើប្រាក់ចំណេញ | ២០ | (៧៧.១៤៦) | (៣០៩.៩៧១) | (១២.៧៥៥) | (៥១.៤៩២) |
| **ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ** | | **៤៥៤.៥២០** | **១.៨២៦.២៦២** | **១៣៤.៥១៨** | **៥៤៣.០៤៩** |

# របាយការណ៍បម្រែបម្រួលមូលធន

*សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨*

| | ដើមទុន ដុល្លារអាមេរិក | ប្រាក់ខាតបង្គរ ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|
| សមតុល្យនាថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧ | ៧.០០០.០០០ | (៥៩៨.៣៥៧) | ៦.៤០១.៦៤៣ |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | ១៣៤.៥១៨ | ១៣៤.៥១៨ |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧** | **៧.០០០.០០០** | **(៤៦៣.៨៣៩)** | **៦.៥៣៦.១៦១** |
| (សមមូលពាន់រៀល - កំណត់សម្គាល់ ៥) | **២៨.២៥៩.០០០** | **(១.៨៧២.៥២២)** | **២៦.៣៨៦.៤៧៨** |
| សមតុល្យនាថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ | ៧.០០០.០០០ | (៤៦៣.៨៣៩) | ៦.៥៣៦.១៦១ |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | ៤៥៤.៥២០ | ៤៥៤.៥២០ |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨** | **៧.០០០.០០០** | **(៩.៣១៩)** | **៦.៩៩០.៦៨១** |
| (សមមូលពាន់រៀល - កំណត់សម្គាល់ ៥) | **២៨.១២៦.០០០** | **(៣៧.៤៤៤)** | **២៨.០៨៨.៥៥៦** |

# របាយការណ៍លំហូរសាច់ប្រាក់

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨

| | កំណត់សំគាល់ | ដុល្លារអាមេរិក | ៣១ ធ្នូ ២០១៨ ពាន់រៀល (កំណត់សំគាល់ ៥) | ដុល្លារអាមេរិក | ៣១ ធ្នូ ២០១៧ ពាន់រៀល (កំណត់សគាល់ ៥) |
|---|---|---|---|---|---|
| **លំហូរទឹកប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | | ៤៥៤.៥២០ | ១.៨២៦.២៦២ | ១៣៤.៥១៨ | ៥៤៣.០៤៩ |
| និយ័តភាពលើ៖ | | | | | |
| រំលស់លើទ្រព្យ និងបរិក្ខារ | | ៩៨.៨៩២ | ៣៩៧.៣៤៨ | ១៤៩.៩៧០ | ៦០៥.៤២៩ |
| រំលស់លើទ្រព្យសកម្មអរូបី | | ៨.២៥០ | ៣៣.១៤៩ | ៩.១៦៧ | ៣៧.០០៦ |
| ចំណេញពីការលក់ទ្រព្យ និងបរិក្ខារ | | (២០.០៨១) | (៨០.៦៨៥) | - | - |
| ការលុបចោលទ្រព្យ និងបរិក្ខារ | | ១៣៧ | ៥៥១ | ១០២ | ៤១២ |
| សំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យ | | ១២៨.០៤៨ | ៥១៤.៤៩៧ | - | - |
| ចំណាយពន្ធលើប្រាក់ចំណេញ | | ៧៧.១៤៦ | ៣០៩.៩៧១ | ១២.៧៥៥ | ៥១.៤៩២ |
| | | ៧៤៦.៩១២ | ៣.០០១.០៩៣ | ៣០៦.៥១២ | ១.២៣៧.៣៨៨ |
| ការប្រែប្រួលនៃ៖ | | | | | |
| ឥណទានផ្តល់ដល់អតិថិជន | | (២.១០៧.១៤០) | (៨.៤៦៦.៤៨៩) | (៤.៣៥០.៤២៧) | (១៧.៥៦២.៦៧៤) |
| ទ្រព្យសកម្មផ្សេងៗ | | (៣៧.២៧៣) | (១៤៩.៧៦៣) | (២៣.២៤៦) | (៩៣.៨៤៤) |
| បំណុលផ្សេងៗ | | ១២១.៨១៧ | ៤៨៩.៤៦១ | ៨៩.៥៣៨ | ៣៦១.៤៦៦ |
| សាច់ប្រាក់ប្រើប្រាស់ក្នុងប្រតិបត្តិការ | | (១.២៧៥.៦៨៤) | (៥.១២៥.៦៩៨) | (៣.៩៧៧.៦២៣) | (១៦.០៥៧.៦៦៤) |
| ពន្ធលើប្រាក់ចំណេញបានបង់ | | (១៧.០៩២) | (៦៨.៦៧៦) | (១២.៤៦០) | (៥០.៣០១) |
| សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពប្រតិបត្តិការ | | (១.២៩២.៧៧៦) | (៥.១៩៤.៣៧៤) | (៣.៩៩០.០៨៣) | (១៦.១០៧.៩៦៥) |
| **លំហូរទឹកប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ការទិញទ្រព្យ និងបរិក្ខារ | ១១ | (៧.៨៨៥) | (៣១.៦៨២) | (១២.៤៨៦) | (៥០.៤០៦) |
| សាច់ប្រាក់ទទួលបានពីការលក់ទ្រព្យ និងបរិក្ខារ | | ៥៨.០៥២ | ២៣៣.២៥២ | - | - |
| សាច់ប្រាក់សុទ្ធទទួលបានពី/(ប្រើប្រាស់ក្នុង) សកម្មភាពវិនិយោគ | | ៥០.១៦៧ | ២០១.៥៧០ | (១២.៤៨៦) | (៥០.៤០៦) |
| **លំហូរទឹកប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| បុរេប្រទានពីភាគទុនិក | ១៥ | ៤៩០.០០០ | ១.៩៦៨.៨២០ | ៦០០.០០០ | ២.៤២២.២០០ |
| សាច់ប្រាក់ទទួលបានពីកម្ចី | | ៣.៣៦៧.០០០ | ១៣.៥២៨.៦០៦ | ៣.៦៧១.៤៦១ | ១៤.៨២១.៦៨៧ |
| ការទូទាត់ប្រាក់កម្ចី | | (២.៨០០.០០០) | (១១.២៥០.៤០០) | - | - |
| **សាច់ប្រាក់សុទ្ធទទួលបានពីសកម្មភាពហិរញ្ញប្បទាន** | | ១.០៥៧.០០០ | ៤.២៤៧.០២៦ | ៤.២៧១.៤៦១ | ១៧.២៤៣.៨៨៧ |
| **ការ(ថយចុះ)/កើនឡើងសុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាកសមមូល** | | (១៨៥.៦០៩) | (៧៤៥.៧៧៨) | ២៦៨.៨៩២ | ១.០៨៥.៥១៦ |
| **សាច់ប្រាក់និងសាច់ប្រាក់សមមូល នាដើមការិយបរិច្ឆេទ** | | ៤៩៥.៤៧១ | ២.០០០.២១៦ | ២២៦.៥៧៩ | ៩១៤.៧០០ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (៩.៤១៣) | - | - |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាចុងការិយបរិច្ឆេទ** | | **៣០៩.៨៦២** | **១.២៤៥.០២៥** | **៤៩៥.៤៧១** | **២.០០០.២១៦** |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមាន** | | | | | |
| សាច់ប្រាក់ក្នុងដៃ | | ២២.១៩០ | ៨៩.១៥៩ | ៨.៥៨៩ | ៣៤.៦៧៤ |
| សមទុល្យនៅធនាគារជាតិនៃកម្ពុជា (មិនរួមបញ្ចូលប្រាក់តម្កល់តាមច្បាប់) | | ៨១ | ៣២៥ | ១.២៨២ | ៥.១៧៥ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនានា | | ២៨៧.៥៩១ | ១.១៥៥.៥៤១ | ៤៨៥.៦០០ | ១.៩៦០.៣៦៧ |
| | | **៣៩០.៨៦២** | **១.២៤៥.០២៥** | **៤៩៥.៤៧១** | **២.០០០.២១៦** |




# ព្រឹត្តិការណ៍ ហ្វូតាបា

១. សិក្ខាសាលាបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៨ និងទិសដៅសម្រាប់អនុវត្តឆ្នាំបន្តបន្ទាប់របស់គ្រឹះស្ថាន ហ្វូតាបា
២. កម្មវិធីអបអរសាទរលទ្ធផលប្រលងមធ្យមសិក្សាទុតិយភូមិ អមជាមួយវេទិកាតម្រង់ទិសការសិក្សា



# សិក្ខាសាលាបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៨ និងទិសដៅសម្រាប់អនុវត្តឆ្នាំបន្តបន្ទាប់របស់ គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី

គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បានរៀបចំសិក្ខាសាលាបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៨ និងទិសដៅសម្រាប់អនុវត្តឆ្នាំបន្តបន្ទាប់ ដែលបានប្រព្រឹត្តទៅឡើងនៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៨ នៅរាជធានីភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់លោក **ច្រឹក ផល្លី** ប្រធានក្រុមប្រឹក្សាភិបាល លោក **ចាប រតនា** ទីប្រឹក្សានាយកប្រតិបត្តិ លោក **ព្រាប កណ្ដឹង** ជំនួយការនាយកប្រតិបត្តិ លោក **អ៊ុំ ពិសិដ្ឋ** ជំនួយការនាយកប្រតិបត្តិ លោក លោកស្រី ជានាយក/នាយិកានាយកដ្ឋាន និងពីគ្រប់បុគ្គលិកទាំងអស់នៃគ្រួសារ**ហ្វូតាបា** ដើម្បីបង្ហាញពីសមិទ្ធផលដែលសម្រេចបានក្នុង ឆ្នាំ២០១៨ និងផែនការយុទ្ធសាស្ត្រសម្រាប់ឆ្នាំបន្តបន្ទាប់ ក៏ដូចជាការថ្លែងអំណរគុណដល់ការខិតខំ ប្រឹងប្រែងរបស់បុគ្គលិកគ្រប់លំដាប់ថ្នាក់ដែលបានចូលរួមយ៉ាងសកម្មក្នុងរយៈពេលកន្លងមក។

លោក **ច្រឹក ផល្លី** ប្រធានក្រុមប្រឹក្សាភិបាល បានសម្ដែងនូវសេចក្តីសោមនស្សរីករាយឥតឧបមា ចំពោះការអញ្ជើញជាកិត្តិយសឲ្យចូលរួមនៃអង្គសិក្ខាសាខានៅថ្ងៃនេះ។ ឆ្លៀតក្នុងឱកាសនេះផងដែរលោកក៏បានចែករំលែកនូវពត៌មាននៃវឌ្ឍនភាពសេដ្ឋកិច្ចកម្ពុជា ក្នុងវិស័យធនាគារហិរញ្ញវត្ថុដែលកំពុងមានការរីកចម្រើនគួរអោយគត់សម្គាល់បំផុត ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ក្នុងនោះដែរលោកបានសង្កេតឃើញថា គ្រឹះស្ថាន **ហ្វូតាបា** សម្រេចបានលទ្ធផលដ៏ល្អប្រសើរក្នុងរយៈពេល ៣ឆ្នាំកន្លងមកនេះ ដោយគ្រឹះស្ថានរក្សាបាននូវកម្រិតហានិភ័យនៃផលប័ត្រឥណទាន 0.00% និងអតិថិជនយឺតយ៉ាវដែលត្រូវកាត់ចេញពីបញ្ជីក្នុងអត្រាសូន្យភាគរយ ដែលជាលទ្ធផលមួយដ៏ល្អប្រសើរបំផុតលើការគ្រប់គ្រងឥណទាន ដែលយើងបានបញ្ចេញនៅក្នុងឆ្នាំនីមួយៗ។ លទ្ធផលដ៏ត្រចះត្រចង់ទាំងនេះទទួលបានដោយមានការចូលរួមសហការពីបុគ្គលិកគ្រប់ផ្នែក និងពិសេសផ្នែកឥណទានផ្ទាល់ដែលបានខិតខំប្រឹងប្រែងក្នុងការគ្រប់គ្រង និងដោះស្រាយឱ្យបានទាន់ពេលវេលា។

លោកបណ្ឌិត **ចាប រតនា** ដែលជាទីប្រឹក្សានាយកប្រតិបត្តិ បានមានប្រសាសន៍ថា លោកពិតជាមានសេក្តីសោមនស្សរីករាយណាស់ ដោយមើលឃើញពីការរីកចម្រើនរបស់គ្រឹះស្ថាន **ហ្វូតាបា** ជាលំដាប់តាមរយៈកំណើននៃបុគ្គលិក ការពង្រីកតំបន់ប្រតិបត្តិការ ការបង្កើនផលិតផល និងសេវាហិរញ្ញវត្ថុបន្ថែម ដើម្បីអនុលោមតាមបេសកកម្ម និងទស្សនវិស័យរបស់ខ្លួន គឺជាស្ថាប័នហិរញ្ញវត្ថុឈានមុខគេក្នុងប្រទេសកម្ពុជា ដែលលើកស្ទួយឲ្យល្អប្រសើរនូវកម្រិតជីវភាពរស់នៅរបស់អតិថិជននាពេលបច្ចុប្បន្ន និងអ្នកជំនាន់ថ្មី ក៏ដូចជាផ្តល់ជូននូវសេវាកម្មហិរញ្ញវត្ថុដែលទុកចិត្តបំផុតទៅកាន់សហគ្រាស ខ្នាតមធ្យម ខ្នាតតូច ខ្នាតតូចបំផុត និងរូបវន្តបុគ្គលដោយបង្កើតនូវទីផ្សារដែលមានស្ថិរភាព ដើម្បីគាំទ្រទាំងអតិថិជននាពេលបច្ចុប្បន្ន និងអ្នកជំនាន់ថ្មី ព្រមទាំងចូលរួមក្នុងសកម្មភាពសង្គមដើម្បីសម្រេចនូវគោលបំណង ឬក្តីសុបិនរបស់ពួកគាត់ជាមួយអនាគតដ៏ប្រសើរ។

លោក **ព្រាប កណ្ដឹង** ដែលជាជំនួយការនាយកប្រតិបត្តិ ក៏បានបង្ហាញនូវរបាយការណ៍ហិរញ្ញវត្ថុ សំខាន់ៗមួយចំនួន ដូចជា ទិដ្ឋភាពទូទៅរបស់គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ជូនដល់គ្រប់ បុគ្គលិកទាំងអស់បានជ្រួតជ្រាបអំពី សុខភាពហិរញ្ញវត្ថុ ផែនការយុទ្ធសាស្ត្រ និងការទទួលខុសត្រូវរបស់លោកក្នុងការគ្រប់គ្រង ៣ នាយកដ្ឋាន រួមមាន នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានព័ត៌មានវិទ្យា និងនាយកដ្ឋានធនធានមនុស្ស និងរដ្ឋបាល ព្រមទាំងគ្រប់គ្រងដោយ ប្រយោលលើនាយកដ្ឋានច្បាប់ និងប្រតិបត្តិតាម។ លើសពីនេះទៅទៀត លោកក៏បានចែករំលែកនូវចំណេះដឹង និងបទ ពិសោធន៍មួយចំនួនដែលបានធ្វើឲ្យគ្រឹះស្ថាន **ហ្វូតាបា** មានដំណើការល្អរហូតសម្រេចបាននូវសមិទ្ធផលការងារដ៏ល្អដូច ថ្ងៃនេះ។ ទន្ទឹមនឹងនោះដែរ លោកក៏បានផ្ដាំផ្ញើដល់បុគ្គលិកទាំងអស់ សូមយកចិត្តទុកដាក់បំពេញការងារបន្ថែមទៀត ដើម្បី នាំនាវាគ្រឹះស្ថាន **ហ្វូតាបា** មួយនេះឲ្យទទួលបានលទ្ធផលល្អប្រសើរ និងការរីកចម្រើនបន្ថែមទៀតនាពេលអនាគត។

បន្ថែមលើនេះទៀត លោក **អ៊ុំ ពិសិដ្ឋ** ដែលជាជំនួយការនាយកប្រតិបត្តិ ក៏បានសង្ខេបនូវសមិទ្ធផលអាជីវកម្មដែល សម្រេចបានក្នុងឆ្នាំ២០១៨សម្រាប់នាយកដ្ឋានចំនួន ៣ក្រោមការទទួលខុសត្រូវ និងគ្រប់គ្រងរបស់លោក រួមមាន នាយកដ្ឋានឥណទាន នាយកដ្ឋានទីផ្សារ និងនាយកដ្ឋានប្រតិបត្តិការ។ លោកក៏បានបង្ហាញជូននូវចំនុចខ្លាំងមួយចំនួន ដែលគ្រឹះស្ថានសម្រេចបានសមិទ្ធផលដ៏ល្អៗទាំងអស់នេះ ដោយសារតែគ្រប់បុគ្គលិកទាំងអស់បានសហការក្នុងការគ្រប់ គ្រងគុណភាព និងសុខភាពឥណទានបាន ទាន់ពេលវេលា កំណើននៃផលប័ត្រឥណទានពីមួយឆ្នាំទៅមួយឆ្នាំ ការគ្រប់គ្រង នូវអត្រាហានិភ័យផលប័ត្រឥណទាន (PAR) ក៏ដូចជាអត្រាបំណុលកាត់ចេញពីបញ្ជីក្នុងកម្រិត (Loan Writhen-off) 0.00% ក្នុងរយៈពេល៣ឆ្នាំជាប់ៗគ្នាតែម្ដង។ លោកក៏បានបន្ថែមទៀតថា គ្រឹះស្ថាន **ហ្វូតាបា** នឹងបន្តខិតខំសម្រិតសម្រាំងផ្ដល់ នូវផលិតផល និងសេវាកម្មឱ្យកាន់តែប្រសើរបំផុតជូនដល់អតិថិជនទាំងអស់នាពេលខាងមុខនេះ ពោលគឺអតិថិជន និង **ហ្វូតាបា** មានក្ដីសុបិនរួមគ្នាតែមួយ។

ក្នុងឱកាសដ៏មហោឡារិកនេះ គណៈកម្មាធិការរៀបចំសិក្ខាសាលា ក៏បានរៀបចំកម្មវិធីពិសេសៗមួយចំនួនដូចជាការ ប្រគល់ពានរង្វាន់ជូនដល់ថ្នាក់ដឹកនាំឆ្នើម បុគ្គលិកឆ្នើម និងការប្រគល់លិខិតសរសើរមន្ត្រីឥណទាន កម្មវិធីចាប់រង្វាន់ និងពិសារអាហារសាមគ្គីនៃគ្រួសារបុគ្គលិក**ហ្វូតាបា**៕


















# កម្មវិធីអបអរសាទរលទ្ធផលប្រលងមធ្យមសិក្សាទុតិយភូមិ អមជាមួយវេទិកាតម្រង់ទិសការសិក្សា

នៅថ្ងៃទី១៥ - ១៦ ខែកញ្ញា ឆ្នាំ២០១៨ គ្រឹះស្ថាន **ហ្វូតាបា** បានចូលរួមជាមួយសហភាពសហព័ន្ធយុវជនកម្ពុជា ដែលប្រព្រឹត្តិទៅនៅអគារខេមរានី ទីស្នាក់ការកណ្តាល ស.ស.យ.ក រាជធានីភ្នំពេញ ស្តីពីការអបអរសាទរលទ្ធផលប្រលងមធ្យមសិក្សាទុតិយភូមិ អមជាមួយវេទិកាតម្រង់ទិសការសិក្សា។ គោលបំណងនៃកម្មវិធីនេះ ធ្វើឡើងដើម្បីជួយតម្រង់ទិស និងចែករំលែកបទពិសោធន៍ល្អៗ ដល់ប្អូនៗសិស្សានុសិស្សដែលទើបនឹងប្រលងជាប់មធ្យមសិក្សាទុតិយភូមិ។

ឯកឧត្តម **សាយ សំអាល់** ប្រធានសហភាពសហព័ន្ធយុវជនកម្ពុជារាជធានីភ្នំពេញ បានមានប្រសាសន៍ថាក្រោយប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ជាធម្មតាប្អូនៗសិស្សានុសិស្សត្រូវបន្តការសិក្សានៅកម្រិតឧត្តមសិក្សា និងចាប់យកជំនាញណាមួយទៅតាមចំណង់ចំណូលចិត្ត ដើម្បីកសាងអនាគតរបស់ខ្លួន ក៏ដូចជាជួយប្រទេសជាតិ។

ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ ជួនណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា បានផ្តល់ជាអនុសាសន៍ថា ចំពោះប្អូនៗដែលប្រឡងជាប់ ឬមិនជាប់ អាចសម្រេចចិត្តក្នុងការបន្តការសិក្សាផ្នែកជំនាញវិជ្ជាជីវៈទៅតាមចំណង់ចំណូលចិត្តរៀងៗខ្លួន ជាពិសេសការជ្រើសរើសមុខជំនាញស្របទៅតាមតម្រូវការទីផ្សារបច្ចុប្បន្ន។

ហើយក្នុងកម្មវិធីនោះ ក៏មានការចូលរួមពីស្ថាប័នធនាគារ ស្ថាប័នមីក្រូហិរញ្ញវត្ថុក៏ដូចជាក្រុមហ៊ុនផ្សេងៗទៀត ដែលមានការដាក់ស្តង់បង្ហាញពីផលិតផល និងសេវាកម្មរបស់ខ្លួន។ ហើយក្នុងនោះគ្រឹះស្ថាន **ហ្វូតាបា** បានធ្វើការផ្សព្វផ្សាយអំពីផលិតផល សេវាកម្ម និងការផ្តល់ឱកាសដើម្បីសម្ភាសន៍ចូលបម្រើការងារក្នុងគ្រឹះស្ថាន **ហ្វូតាបា** ភ្លាប់ៗផងដែរ។


















0.125 %



# អតិថិជនរបស់ ហ្វូតាបា

## អ្នកស្រី ឈុន ចាន់ណាក់

លោក **ឡាយ វុត្ថា** មានអាយុ ៤៤ ឆ្នាំ ជាអ្នកបើកបររថយន្តឲ្យក្រុមហ៊ុនឯកជន រីឯប្រពន្ធរបស់គាត់ឈ្មោះ **ឈុន ចាន់ណាក់** អាយុ ៣៧ឆ្នាំ ជាអ្នកលក់ចាបហ៊ួយ មានទីលំនៅក្រុមទី៨ ភូមិគោកឃ្លាង សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ។ ពួកគាត់បានប្រើប្រាស់សេវាកម្មរបស់ **ហ្វូតាបា** អស់រយៈពេលជាច្រើនឆ្នាំមកហើយ។ ដោយមើលឃើញឱកាសរកស៊ីបន្ថែម និងទីតាំងអំណោយផលផងនោះ អ្នកស្រីបានធ្វើការស្នើឥណទានអាជីវកម្មពីគ្រឹះស្ថាន **ហ្វូតាបា** ក្នុងគោលបំណងបើកស្ថានីយ៍ប្រេងឥន្ធនៈ ដើម្បីរកចំណូលប្រចាំថ្ងៃបន្ថែម។ អ្នកស្រីបន្ថែមថា «ដោយសារការខិតខំប្រឹងប្រែងក្នុងមុខជំនួញ និងដោយបានទុនបន្ថែមពី **ហ្វូតាបា** បានធ្វើឲ្យមុខរបររបស់ខ្ញុំមានការរីកចម្រើន និងមានប្រាក់ចំណេញកើនឡើងផងដែរ»។




## លោក កែវ មុន្នី

លោក **កែវ មុន្នី** ជាអាជីវករម្នាក់ ដែលមានអាយុ ៥៥ ឆ្នាំ មានទីលំនៅភូមិ៦ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ។ ដោយមើលឃើញនៅសក្តានុពល និងឱកាសរកចំណូលបន្ថែម លោកក៏បានស្នើឥណទានជាថ្មីម្តងទៀតពី **ហ្វូតាបា** ក្នុងគោលបំណងពង្រីកអាជីវកម្ម និងបង្កើនការបោះដុំផ្កាស្រស់បន្តឲ្យគ្រប់ ២៤ ខេត្ត-ក្រុង នៃប្រទេសកម្ពុជា។ ក្រៅពីការនាំចូលផ្កាស្រស់ពីប្រទេសវៀតណាម លោកក៏បានធ្វើការនាំចូលផ្កាស្រស់ពីប្រទេសថៃ ចិន និងបណ្តាលប្រទេសមួយចំនួនទៀតដើម្បីបំពេញសេចក្តីត្រូវការអតិថិជនឲ្យកាន់តែមានភាពងាយស្រួល ហើយក្រៅពីនេះលោកក៏មានបម្រើសេវាកម្មផ្នែកតុបតែងផ្កាស្រស់ក្នុង កម្មវិធីផ្សេងៗផងដែរ ។ លោកបានបន្តថា «ខ្ញុំសូមអរគុណចំពោះ **ហ្វូតាបា** ដែលបានសម្រេចក្តីសុបិនរបស់ខ្ញុំ ដោយសព្វថ្ងៃនេះសេវាកម្មបោះដុំ និងចែកចាយផ្កាស្រស់ បានដល់អតិថិជនទូទាំងប្រទេសកម្ពុជា»។



## លោក សាយ ឃឹម

*លោក **សាយ ឃឹម** អាយុ ៥០ឆ្នាំ មុខរបរជាជាងធ្វើផ្ទះ និងអ្នកស្រី **មួង ចន្ទ** អាយុ ៥៤ឆ្នាំ មុខរបរជាអ្នកចិញ្ចឹមជ្រូក ពួកគាត់ជាអតិថិជនរបស់គ្រឹះស្ថាន **ហ្វូតាបា** ដែលមានទីលំនៅ ភូមិក្រសាំងតាគង់ ឃុំនិទាន ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ។ ដោយមើលឃើញនូវឱកាសរកប្រាក់ចំណូលបន្ថែម លោក ឃឹម និងប្រពន្ធរបស់គាត់ក៏បានសម្រេចចិត្តស្នើសុំឥណទានកសិកម្មរបស់ **ហ្វូតាបា** ជាលើកទីពីរ ក្នុងគោលបំណងទិញម៉ាស៊ីនកិនស្រូវ ដើម្បីរកចំណូលបន្ថែមពីក្នុងភូមិ។ ក្រៅពីនេះទៀត គាត់ និងប្រពន្ធរបស់គាត់បានចិញ្ចឹមជ្រូកបន្ថែមដើម្បីលក់ និងដោះស្រាយពេលត្រូវការសាច់ប្រាក់បន្ទាន់។ លោកបាននិយាយថា «ដោយសារតែគ្រឹះស្ថាន **ហ្វូតាបា** បានផ្តល់ប្រាក់កម្ចីឲ្យខ្ញុំបាទ ទើបធ្វើឲ្យប្រាក់ចំណូលមានការកើនឡើង និងជីវភាពគ្រួសាររបស់ខ្ញុំមានភាពប្រសើរឡើងដូចសព្វថ្ងៃនេះ។ ខ្ញុំសូមថ្លែង អំណរគុណដល់គ្រឹះស្ថាន **ហ្វូតាបា** ដែលជាដៃគូហិរញ្ញវត្ថុដ៏ល្អសម្រាប់គ្រួសាររបស់ខ្ញុំ និងសូមឲ្យគ្រឹះស្ថាន **ហ្វូតាបា** មានការរីកចម្រើនតទៅមុខទៀត»។*




## អ្នកស្រី វ៉ន សុគន្ធា

អ្នកស្រី **វ៉ន សុគន្ធា** អាយុ ៣១ឆ្នាំ មានមុខរបរជាអ្នកលក់ចាប់ហ៊ួយ និងជាងផាត់មុខធ្វើសក់ មានទីលំនៅភូមិថ្មគោល សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។ ដោយមានការផ្សព្វផ្សាយផលិតផល និងសេវាកម្មយ៉ាងទូលំទូលាយរបស់គ្រឹះស្ថាន **ហ្វូតាបា** តាមរយៈមន្ត្រីឥណទាន បានធ្វើឲ្យអ្នកស្រីមានការចាប់អារម្មណ៍ជាខ្លាំងលើឥណទានរបស់គ្រឹះស្ថាន **ហ្វូតាបា** ដោយមានលក្ខខ័ណ្ឌល្អ និងអត្រាការប្រាក់សមរម្យជាងស្ថាប័នផ្សេងៗ គាត់ក៏បានស្នើឥណទានប្រើប្រាស់ផ្ទាល់ខ្លួន ដើម្បីធ្វើការជួលជុលផ្ទះ ធ្វើបន្ទប់ជួល និងពង្រីកមុខរបរបន្ថែម។ មកដល់សព្វថ្ងៃនេះ ក្រៅពីប្រាក់ចំណូលពីការលក់ចាប់ហ៊ួយ ផាត់មុខធ្វើសក់ អ្នកស្រីក៏បានទទួលប្រាក់ចំណូលប្រចាំខែពីមានបន្ទប់ជួលជាច្រើនរបស់គាត់។



# ដៃគូសហប្រតិបត្តិការ របស់ ហ្វូតាបា

# ដៃគូប្រតិបត្តិការ

FORTE INSURANCE

FutureBud International

ប.ស.ស NSSF National Social Security Fund

CBC

truemoney

Wing



០៧០ ៣១២ ៣៣៣


អាសយដ្ឋាន៖
អគារលេខ ៧៩៥ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក
ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ: ០២៣ ២២៤ ៣៣៣ ទូរសារ: ០២៣ ២២២ ១៣១
អ៊ីម៉ែល: info@futabamfi.com.kh
គេហទំព័រ: www.futabamfi.com.kh
ហ្វេសបុក: Futaba Microfinance Plc.